7. Where, by reason of a special relationship between the payer and the beneficial owner or between both of them and some other person, the amount of the interest, having regard to the debt-claim for which it is paid, exceeds the amount which would have been agreed upon by the payer and the beneficial owner in the absence of such relationship, the provisions of this Article shall apply only to the last-mentioned amount. In such case, the excess part of the

payments shall remain taxable according to the laws of each Contracting State, due regard being had to the other provisions of this Agreement.

ARTICLE 12

ROYALTIES

1. Royalties arising in a Contracting State and paid to a resident of the other Contracting State may be taxed in that other State.

2. However, such royalties may also be taxed in the Contracting State in which they arise and according to the laws of that State, but if the beneficial owner of the royalties is a resident of the other Contracting State, the tax so charged shall not exceed 10 per cent of the gross amount of the royalties.

3. The term "royalties" as used in this Article means payments of any kind received as a consideration for the use of, or the right to use, any copyright of literary, artistic or scientific work including cinematograph films, or films or tapes used for radio or television broadcasting, any patent, trademark, design or model, plan, secret formula or process, or for the use of, or the right to use, industrial, commercial or scientific equipment or for information concerning industrial, commercial or scientific experience.

4. The provisions of paragraphs 1 and 2 of this Article shall not apply if the beneficial owner of the royalties, being a resident of a Contracting State, carries on business in the other Contracting State in which the royalties arise through a permanent establishment situated therein, or performs in that other State independent personal services from a fixed base situated therein, and the right or property in respect of which the royalties are paid is effectively connected with (a) such permanent establishment or fixed base, or with (b) business activities referred to in (c) of paragraph 1 of Article 7. In such case, the provisions of Article 7 or Article 15, as the case may be, shall apply.

5. Royalties shall be deemed to arise in Contracting State when the payer is a resident of that State. Where, however, the person paying the royalties, whether he is a resident of a Contracting State or not, has in a Contracting State a permanent establishment or a fixed base in connection with which the liability to pay the royalties was incurred, and such royalties are borne by such permanent establishment or fixed base, then such royalties shall be deemed

to arise in the State in which the permanent establishment or fixed base is situated.

6. Where, by reason of a special relationship between the payer and the beneficial owner or between both of them and some other person, the amount of the royalties, having regard to the use, right, or information for which they are paid, exceeds the amount which would have been be agreed upon between the payer and beneficial owner in the absence of such relationship, the provisions of this Article shall apply only to the last-mentioned amount. In such case, the excess part of the payments shall remain taxable according to the laws of each Contracting State, due regard being had to the other provisions of this Agreement.

## ARTICLE 13

## FEES FOR TECHNICAL SERVICES

1. Fees for technical services arising in a Contracting State which are derived by a resident of the other Contracting State may be taxed in that other State.

2. However, fees for technical services may also be taxed in the Contracting State in which they arise, and according to the laws of that State, but if the recipient is the beneficial owner of the fees for technical services, the tax so charged shall not exceed 10 per cent of the gross amount of the fees for technical services.

3. The term "fees for technical services" means payment of any kind in consideration for the rendering of any managerial, technical or consultancy services, including the provision by the enterprise of the services of technical or other personnel, but does not include payments for services to which Article 16 of this Agreement applies.

4. The provisions of paragraph 1 of this Article shall not apply if the beneficial owner of the fees for technical services, being a resident of a Contracting State, carries on business in the other Contracting State in which the fees for technical services arise through a permanent establishment situated therein, and the fees for technical services are effectively connected with (a) such permanent establishment, or with (b) business activities referred to in (c) of paragraph 1 of Article 7. In such case, the provisions of Article 7 shall apply.

5. Fees for technical services shall be deemed to arise in a Contracting State when the payer is a resident of that State. Where, however, the person paying the fees for technical services, whether he is a resident of a Contracting State or not, has in a Contracting State a permanent establishment or a fixed base in connection with which the obligation to pay the fees for technical services was incurred, and such fees for technical services are borne by such permanent establishment or fixed base, then such fees for technical services shall be deemed to arise in the Contracting State in which the permanent establishment or fixed base is situated.

6. Where, by reason of a special relationship between the payer and the beneficial owner or between both of them and some other person, the amount of the fees for technical services paid exceeds, for whatever reason, the amount which would have been agreed upon by the payer and the beneficial owner in the absence of such relationship, the provisions of this Article shall only apply to the last-mentioned amount. In such case, the excess part of the payments shall remain taxable according to the law of each Contracting State, due regard being had to the other provisions of this Agreement.

## ARTICLE 14

## CAPITAL GAINS

1. Gains derived by a resident of a Contracting State from the alienation of immovable property referred to in Article 6 and situated in the other Contracting State may be taxed in that other State.

2. Gains from the alienation of movable property forming part of the business property of a permanent establishment which an enterprise of a Contracting State has in the other Contracting State or of movable property pertaining to a fixed base available to a resident of a Contracting State in the other Contracting State for the purpose of performing independent personal services, including such gains from the alienation of such a permanent establishment (alone or with the whole enterprise) or of such fixed base, may be taxed in that other State.

3. Gains derived by an enterprise of a Contracting State from the alienation of ships or aircraft operated in international traffic or movable property pertaining to the operation of such ships or aircraft shall be taxable only in that State.

4. Gains derived by a resident of a Contracting State from the alienation of shares deriving more than 50 per cent of their value directly or indirectly from immovable property situated in the other Contracting State may be taxed in that other State.

5. Gains from the alienation of any property other than that referred to in the preceding paragraphs of this Article shall be taxable only in the Contracting State of which the alienator is a resident.

## ARTICLE 15

## INDEPENDENT PERSONAL SERVICES

1. Subject to the provisions of Article 13, income derived by an individual who is a resident of a Contracting State in respect of professional services or other activities of an independent character shall be taxable only in that State except in the following circumstances, when such income may also be taxed in the other Contracting State:

   (a) If he has a fixed base regularly available to him in the other Contracting State for the purpose of performing his activities; in that case, only so much of the income as is attributable to that fixed base may be taxed in that other Contracting State; or

   (b) If his stay in the other Contracting State is for a period or periods amounting to or exceeding in the aggregate 183 days in any 12-month period; in that case, only so much of the income as is derived from his activities performed in that other State may be taxed in that other State.

2. The term "professional services" includes especially independent scientific, literary, artistic, educational or teaching activities, as well as the independent activities of physicians, lawyers, engineers, architects, dentists, and accountants.

## ARTICLE 16

## DEPENDENT PERSONAL SERVICES

1. Subject to the provisions of Articles 17, 19, and 20, salaries, wages, and other similar remuneration derived by a resident of a Contracting State in respect of an employment shall be taxable only in that State unless the employment is exercised in the other Contracting State. If the employment is so exercised, such remuneration as is derived therefrom may be taxed in that other State.

2. Notwithstanding the provisions of paragraph 1, remuneration derived by a resident of a Contracting State in respect of an employment exercised in the other Contracting State shall be taxable only in the first-mentioned State if:

   (a) the recipient is present in the other State for a period or periods not exceeding in the aggregate 183 days in any 12-month; and

   (b) the remuneration is paid by, or on behalf of, an employer who is not a resident of the other State, and

   (c) the remuneration is not borne by a permanent establishment or a fixed base which the employer has in the other State.

3. Notwithstanding the preceding provisions of this Article, remuneration derived in respect of an employment exercised aboard a ship or aircraft operated in international traffic by an enterprise of a Contracting State may be taxed in that State.

ARTICLE 17

DIRECTORS' FEES

1. Directors' fees and other similar payments derived by a resident of a Contracting State in his capacity as a member of the Board of Directors or any other similar organ of a company which is a resident of the other Contracting State may be taxed in that other State.
2. Salaries, wages and other similar remuneration derived by a resident of a Contracting State in his capacity as an official in a top-level managerial position of a company which is a resident of the other Contracting State may be taxed in that other State.

ARTICLE 18

ARTISTES AND SPORTSPERSONS

1. Notwithstanding the provisions of Articles 15 and 16, income derived by a resident of a Contracting State as an entertainer, such as a theatre, motion picture, radio or television artiste, or a musician, or as a sportsperson, from his personal activities as such exercised in the other Contracting State, may be taxed in that other State.

2. Where income in respect of personal activities exercised by an entertainer or a sportsperson in his capacity as such accrues not to the entertainer or sportsperson himself but to another person, that income may, notwithstanding the provisions of Articles 7, 15, and 16, be taxed in the Contracting State in which the activities of the entertainer or sportsperson are exercised.

3. Notwithstanding the provisions of paragraphs 1 and 2 of this Article, income derived in respect of the activities referred to in paragraph 1 of this Article within the framework of cultural or sports exchange program agreed upon by both Contracting States shall be exempt from tax in the Contracting State in which these activities are exercised.

ARTICLE 19

PENSIONS, ANNUITIES, AND SOCIAL SECURITY PAYMENTS

1. Subject to the provisions of paragraph 2 of Article 20, pensions, annuities, and other similar remuneration paid to a resident of a Contracting State in consideration of past employment may be taxed in that State.

2. However, such pensions, annuities, and other similar remuneration may also be taxed in the other Contracting State if the payment is made by a resident of that other State or a permanent establishment situated therein.

   The term "annuity" means a stated sum payable periodically at stated times during life of the annuitant or during a specified or ascertainable period of time under an obligation to make the payments in return for adequate and full consideration in money or money's worth.

3. Notwithstanding the provisions of paragraphs 1 and 2, pensions paid and other payments made under a public scheme which is part of the social security system of a Contracting State or a local authority thereof shall be taxable only in that State.

## ARTICLE 20

## GOVERNMENT SERVICE

1. (a) Salaries, wages and other similar remuneration paid by a Contracting State or a local authority or a statutory body thereof to an individual in respect of services rendered to that State or authority or statutory body shall be taxable only in that State.

   (b) However, such salaries, wages and other similar remuneration shall be taxable only in the other Contracting State if the services are rendered in that State and the individual is a resident of that State who:

   (i) is a national of that State; or

   (ii) did not become a resident of that State solely for the purpose of rendering the services.

2. (a) Notwithstanding the provisions of paragraph 1, pensions and other similar remuneration paid by, or out of funds created by, a Contracting State or a local authority thereof to an individual in respect of services rendered to that State or authority or statutory body shall be taxable only in that State.

   (b) However, such pensions and other similar remuneration shall be taxable only in the other Contracting State if the individual is a resident of, and a national of, that other State.

3. The provisions of Articles 16, 17, 18 and 19 shall apply to salaries, wages, pensions, and other similar remuneration in respect of services rendered in connection with a business carried on by a Contracting State or a local authority or a statutory body thereof.

## ARTICLE 21

## STUDENTS AND TRAINEES

1. Payments which a student, business apprentice, or trainee who is or was immediately before visiting a Contracting State a resident of the other Contracting State and who is present in the first-mentioned State solely for the purpose of his education or training receives for the purpose of his maintenance, education, or training shall not be taxed in that State, provided that such payments arise from sources outside that State.
2. In respect of grants, scholarships, and remuneration from employment not covered by paragraph 1, a student or business apprentice or trainee described in paragraph 1 shall in addition be entitled during such education or training to the same exemptions, reliefs, or reductions in respect of taxes available to residents of the State which he is visiting.

ARTICLE 22

TEACHERS AND RESEARCHERS

1. An individual who is or was a resident of a Contracting State immediately before making a visit to the other Contracting State, and who, at the invitation of any university, college, school or other similar educational institution which is recognised by the government, museum or other cultural institution in that other State, is present in that other State for a period not exceeding two consecutive years solely for the purpose of teaching, giving lectures or carrying out research at such institution shall be exempt from tax in that other Contracting State on any remuneration for such activity.

2. The provisions of paragraph 1 shall not apply to income from research if such research is undertaken by the individual primarily for the private benefit of a specific person or persons.

## ARTICLE 23

## OTHER INCOME

1. Items of income of a resident of a Contracting State, wherever arising, not dealt with in the foregoing Articles of this Agreement shall be taxable only in that State.

2. The provisions of paragraph 1 shall not apply to income, other than income from immovable property as defined in paragraph 2 of Article 6, if the recipient of such income, being a resident of a Contracting State, carries on business in the other Contracting State through a permanent establishment situated therein, or performs in that other State independent personal services from a fixed base situated therein and the right or property in respect of which the income is paid is effectively connected with such permanent establishment or fixed base. In such case the provisions of Article 7 or Article 15, as the case may be, shall apply.

3. Notwithstanding the provisions of paragraphs 1 and 2, items of income of a resident of a Contracting State not dealt with in the foregoing Articles of this Agreement and arising in the other Contracting State may also be taxed in that other State.

## ARTICLE 24

## ELIMINATION OF DOUBLE TAXATION

1. Where a resident of a Contracting State derives income which, in accordance with the provisions of this Agreement, may be taxed in the other Contracting State, the first-mentioned Contracting State shall allow as a deduction from the tax on the income of that resident an amount equal to the tax paid in the other Contracting State. Such deduction shall not, however, exceed that part of the income tax, as computed before the deduction is given, which is attributable to the income which may be taxed in that other State.

2. For the purposes of allowance as credit in a Contracting State, the tax paid in the other Contracting State shall be deemed to include the amount of tax which is otherwise payable in that other Contracting State but has been exempted or reduced in accordance with incentive laws and connected regulations designed to promote economic development in that other State.

3. For the purposes of paragraph 1 of this Article, the term "tax paid", in the case of Cambodia, does not include Additional Profit Tax on Dividend Distribution payable in respect of income to which the provisions of paragraph 2 of this Article applies.

## ARTICLE 25

## NON-DISCRIMINATION

1. Nationals of a Contracting State shall not be subjected in the other Contracting State to any taxation or any requirement connected therewith which is other or more burdensome than the taxation and connected requirements to which nationals of that other State in the same circumstances, in particular with respect to residence, are or may be subjected.

2. The taxation on a permanent establishment which an enterprise of a Contracting State has in the other Contracting State shall not be less favourably levied in that other State than the taxation levied on enterprises of that other State carrying on the same activities. This provision shall not be construed as obliging a Contracting State to grant to residents of the other Contracting State any personal allowances, reliefs and reductions for taxation purposes on account of civil status or family responsibilities which it grants to its own residents.

3. Except where the provisions of paragraph 1 of Article 9, paragraph 7 of Article 11, or paragraph 6 of Article 12, paragraph 6 of Article 13 apply, interest, royalties, technical fees and other disbursements paid by an enterprise of a Contracting State to a resident of the other Contracting State shall, for the purpose of determining the taxable profits of such enterprise, be deductible under the same conditions as if they had been paid to a resident of the first-mentioned State.

4. Enterprises of a Contracting State, the capital of which is wholly or partly owned, or controlled, directly or indirectly, by one or more residents of the other Contracting State, shall not be subjected in the first-mentioned State to any taxation or any requirement connected therewith which is other or more burdensome than the taxation and connected requirements to which other similar enterprises of the first-mentioned State are or may be subjected.

5. Nothing contained in the preceding paragraphs of this article shall be construed as affecting any provisions of the laws of the respective Contracting States regarding any tax concessions granted.

6. In this Article, the term "taxation" means taxes which are the subject of this Agreement.

## ARTICLE 26

## MUTUAL AGREEMENT PROCEDURE

1. Where a resident of a Contracting State considers that the actions of one or both of the Contracting States result or will result for him in taxation not in accordance with the provisions of this Agreement, he may, irrespective of the remedies provided by the domestic laws of those States, present his case to the competent authority of the Contracting State of which he is a resident or, if his case comes under paragraph 1 of Article 24, to that of the Contracting State of which he is a national. The case must be presented within three years from the first notification of the action resulting in taxation not in accordance with the provisions of this Agreement.

2. The competent authority shall endeavor, if the objection appears to it to be justified and if it is not itself able to arrive at a satisfactory solution, to resolve the case by mutual agreement with the competent authority of the other Contracting State, with a view to the avoidance of taxation which is not in accordance with this Agreement.

3. The competent authorities of the Contracting States shall endeavor to resolve by mutual agreement any difficulties or doubts arising as to the interpretation or application of the Agreement. They may also consult together for the elimination of double taxation in cases not provided for in the Agreement.

4. The competent authorities of the Contracting States may communicate with each other directly for the purpose of reaching an agreement in the sense of the preceding paragraphs.

ARTICLE 27

EXCHANGE OF INFORMATION

1. The competent authorities of the Contracting States shall exchange such information as is foreseeably relevant for carrying out the provisions of this Agreement or to the administration or enforcement of the domestic laws concerning taxes of every kind and description imposed on behalf of the Contracting States, or of their local authorities, insofar as the taxation thereunder is not contrary to the Agreement. The exchange of information is not restricted by Articles 1 and 2.

2. Any information received under paragraph 1 by a Contracting State shall be treated as secret in the same manner as information obtained under the domestic laws of that State and shall be disclosed only to persons or authorities (including courts and administrative bodies) concerned with the assessment or collection of, the enforcement or prosecution in respect of, the determination of appeals in relation to the taxes referred to in paragraph 1, or the oversight of the above. Such persons or authorities shall use the information only for such purposes. They may disclose the information in public court proceedings or in judicial decisions. Notwithstanding the foregoing, information received by a Contracting State may be used for other purposes when such information may be used for such other purposes under the laws of both States and the competent authority of the supplying State authorises such use.

3. In no case shall the provisions of paragraph 1 and 2 be construed so as to impose on a Contracting State the obligation :

   (a) to carry out administrative measures at variance with the laws and administrative practice of that or of the other Contracting State;

   (b) to supply information which is not obtainable under the laws or in the normal course of the administration of that or of the other Contracting State;

(c) to supply information which would disclose any trade, business, industrial, commercial or professional secret or trade process, or information, the disclosure of which would be contrary to public policy (*ordre public*).

4. If information is requested by a Contracting State in accordance with this Article, the other Contracting State shall use its information gathering measures to obtain the requested information, even though that other State may not need such information for its own tax purposes. The obligation contained in the preceding sentence is subject to the limitations of paragraph 3 but in no case shall such limitations be construed to permit a Contracting State to decline to supply information solely because it has no domestic interest in such information.

5. In no case shall the provisions of paragraph 3 be construed to permit a Contracting State to decline to supply information solely because the information is held by a bank, other financial institution, nominee or person acting in an agency or a fiduciary capacity or because it relates to ownership interests in a person.

## ARTICLE 28

## MEMBERS OF DIPLOMATIC MISSION AND CONSULAR POST

Nothing in this Agreement shall affect the fiscal privileges of members of diplomatic missions or consular posts under the general rules of international law or under the provisions of special agreements.

ARTICLE 29

ENTRY INTO FORCE

This agreement shall enter into force on the latter of the dates on which the respective Contracting States notify each other in writing, through diplomatic channels, the completion of the procedures required by its law or legislation for bringing into force this Agreement. This agreement shall have effect:

(a) in Indonesia:

(i) in respect of taxes withheld at the source to income derived on or after 1 January in the year next following the year in which the Agreement enters into force; and

(ii) in respect of other taxes on income, for taxable years beginning on or after 1 January in the year next following the year in which the Agreement enters into force; and

(b) In Cambodia:

(i) in respect of taxes withheld at source, in relation to taxable amount as derived on or after the first day of January following the calendar year in which the Agreement enters into force and in subsequent calendar years; and

(ii) in respect of other Cambodian taxes, in relation to income arising on or after the first day of January following the calendar year in which the Agreement enters into force, and in subsequent calendar years.

## ARTICLE 30

## TERMINATION

This Agreement shall remain in force until terminated by a Contracting State. Either Contracting State may terminate the Agreement, through diplomatic channels, by giving written notice of termination on or before 30th of June of any calendar year following after the period of five years from the date the Agreement enters into force. In such case, the Agreement shall cease to have effect:

(a) in Indonesia:

(i) in respect of taxes withheld at the source to income derived on or after 1 January in the year next following the year in which the notice of termination is given; and

(ii) in respect of other taxes on income, for taxable years beginning on or after 1 January in the year next following the year in which the notice of termination is given; and

(b) in Cambodia:

(i) in respect of taxes withheld at source, in relation to taxable amount as derived on or after the first day of January following the calendar year in which the notice of termination is given; and

(ii) in respect of other Cambodian taxes, in relation to income arising on or after the first day of January following the calendar year in which the notice of termination is given.

IN WITNESS WHEREOF the undersigned, duly authorized thereto, have signed this Protocol.

DONE in duplicate at Jakarta on 23rd Oct 2017 and at Phnom Penh on 13th Oct 2017 in the Indonesian, Khmer, and English languages, all texts being equally authentic. In the event of any divergence of interpretation, the English text shall prevail.

| For the Government of the Republic of Indonesia | For the Royal Government of Cambodia |
|---|---|
| [signature] | [signature] |
| **Dr. SRI MULYANI INDRAWATI** | **Dr. AUN PORNMONIROTH** |
| **Minister of Finance** | **Senior Minister** |
| | **Minister of Economy and Finance** |

REPUBLIK INDONESIA

# កិច្ចព្រមព្រៀង

# រវាង

# រដ្ឋាភិបាល

# នៃសាធារណរដ្ឋឥណ្ឌូនេស៊ី

# និង

# រាជរដ្ឋាភិបាលនៃ

# ព្រះរាជាណាចក្រកម្ពុជា

# ស្តីពីការចៀសវាង

# ការយកពន្ធត្រួតគ្នា និង

# ការបង្ការការកឹបកេងបន្លំពន្ធ

# ពាក់ព័ន្ធនឹង

# ពន្ធលើប្រាក់ចំណូល

## មាត្រា ១
## វិសាលភាពលើបុគ្គល

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបុគ្គលដែលជានិវាសនជននៃរដ្ឋមួយ ឬរដ្ឋទាំងពីរដែលជាភាគីនៃកិច្ចព្រមព្រៀង។

ក្នុងគោលបំណងបន្តបង្កើនទំនាក់ទំនងសេដ្ឋកិច្ច និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងផ្នែកពន្ធដារ និង ឈានទៅសម្រេចកិច្ចព្រមព្រៀងសម្រាប់លុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានព្រមព្រៀង ដូចតទៅ÷

## មាត្រា ២
## វិសាលភាពនៃពន្ធ

១- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាពន្ធលើប្រាក់ចំណូលដែលកំណត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ ដោយមិនផ្តោតលើវិធាននៃការកំណត់ពន្ធទាំងនោះ។

២- ពន្ធលើប្រាក់ចំណូលសំដៅដល់បណ្តាពន្ធដែលត្រូវបានកំណត់លើចំណូលសរុប ឬចំណែកនៃចំណូល រួមបញ្ចូលទាំងបណ្តាពន្ធលើចំណេញដែលសម្រេចបានមកពីការលក់ ឬផ្ទេរចលនឬអចលនទ្រព្យ និងបណ្តាពន្ធលើប្រាក់ឈ្នួល ឬប្រាក់បៀវត្ស។

៣- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះបណ្តាប្រភេទពន្ធ ដូចខាងក្រោម÷

ក. សម្រាប់ឥណ្ឌូនេស៊ី÷

(i) ពន្ធលើចំណូល

(តទៅនេះហៅកាត់ថា "ពន្ធរបស់ឥណ្ឌូនេស៊ី")

ខ. សម្រាប់កម្ពុជា÷

(i) ពន្ធលើប្រាក់ចំណេញ រួមបញ្ចូលទាំងពន្ធកាត់ទុក ពន្ធអប្បបរមា ពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភ និងពន្ធលើចំណេញមូលធន

(ii) ពន្ធលើប្រាក់បៀវត្ស

គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ អាចរារាំងដល់ការអនុវត្តពន្ធអប្បបរមា

(តទៅនេះហៅកាត់ថា "ពន្ធរបស់កម្ពុជា")។

៤- កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តផងដែរចំពោះប្រភេទពន្ធណាដែលមានចរិតលក្ខណៈដូចគ្នាសុទ្ធសាធ ឬប្រហាក់ប្រហែលគ្នា ដែលបានដាក់ឱ្យអនុវត្តក្រោយកាលបរិច្ឆេទនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ដោយបន្ថែម ឬជំនួសឱ្យប្រភេទពន្ធជាធរមាន ដូចមានចែងក្នុងមាត្រានេះ។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវជូនដំណឹងគ្នាទៅវិញទៅមកនូវរាល់ការធ្វើវិសោធនកម្មសំខាន់ៗ លើច្បាប់ស្តីពីសារពើពន្ធរបស់ខ្លួន។

## មាត្រា ៣
## និយមន័យទូទៅ

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទដែលតម្រូវឱ្យមានអត្ថន័យផ្សេង÷

ក. (i) ពាក្យ "ឥណ្ឌូនេស៊ី" រាប់បញ្ចូលដែនដីនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលមានកំណត់ក្នុងច្បាប់របស់ខ្លួន និងតំបន់នៅជាប់គ្នាដែលសាធារណរដ្ឋឥណ្ឌូនេស៊ីមានអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

(ii) ពាក្យ "កម្ពុជា" សំដៅដល់ដែនអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សមុទ្រ ដែលរួមមាន ខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងដែនសមុទ្រខាងក្រៅ និងដែនអាកាស ហើយដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

ខ. ពាក្យ "រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង" និង "រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត" សំដៅដល់សាធារណរដ្ឋឥណ្ឌូនេស៊ី ឬព្រះរាជាណាចក្រកម្ពុជា តាមតម្រូវការនៃបរិបទ។

គ. ពាក្យ "បុគ្គល" រួមបញ្ចូលរូបវន្តបុគ្គល ក្រុមហ៊ុន និងបុគ្គលដទៃទៀត។

ឃ. ពាក្យ "ក្រុមហ៊ុន" សំដៅដល់នីតិបុគ្គល ឬអង្គភាពណាមួយដែលត្រូវបានចាត់ទុកជានីតិបុគ្គល សម្រាប់គោលដៅពន្ធ។

ង. ពាក្យ "សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង" និង "សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត" សំដៅដល់សហគ្រាសដែលប្រកបអាជីវកម្មដោយនិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងសហគ្រាសដែលប្រកបអាជីវកម្មដោយនិវាសជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ច. ពាក្យ "ចរាចរណ៍អន្តរជាតិ" សំដៅដល់ការដឹកជញ្ជូនតាមនាវា ឬយន្តហោះ ដែលធ្វើប្រតិបត្តិការដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង លើកលែងតែក្នុងករណីនាវា ឬយន្តហោះធ្វើ ប្រតិបត្តិការ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងតែម្ខាងប៉ុណ្ណោះ។

ឆ. ពាក្យ "ជនជាតិ" នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង សំដៅដល់÷

(i) រូបវន្តបុគ្គលទាំងឡាយដែលជាពលរដ្ឋ ឬមានសញ្ជាតិរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ និង

(ii) នីតិបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ឬសមាគមទាំងឡាយណា ដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់ជាធរមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ។

ជ. ពាក្យ "អាជ្ញាធរមានសមត្ថកិច្ច" សំដៅដល់÷

(i) ក្នុងករណីឥណ្ឌូនេស៊ី÷ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងហិរញ្ញវត្ថុ។

(ii) ក្នុងករណីកម្ពុជា÷ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាងពេញសិទ្ធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- សម្រាប់គោលដៅនៃមាត្រា១០ មាត្រា១១ និងមាត្រា១២ បរធនបាលដែលជាប់ពន្ធក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងចំពោះភាគលាភ ការប្រាក់ ឬសួយសារ ត្រូវចាត់ទុកជាម្ចាស់ទទួលផលកម្រៃនៃភាគលាភ ការប្រាក់ ឬសួយសារទាំងនោះ។

៣- ចំពោះការអនុវត្តកិច្ចព្រមព្រៀងដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងពេលដែលពាក្យណាមួយមិនបានកំណត់និយមន័យនៅក្នុងកិច្ចព្រមព្រៀងនេះ ពាក្យនោះត្រូវមានន័យដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋនោះ សម្រាប់គោលដៅយកពន្ធដែលស្របតាមកិច្ចព្រមព្រៀងនេះ វៀរលែងតែមានបរិបទតម្រូវឱ្យមានអត្ថន័យផ្សេង។ និយមន័យនៃពាក្យណាមួយដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធរបស់រដ្ឋនោះ ត្រូវមានវិសាលភាពគ្របដណ្តប់លើនិយមន័យដែលមានចែងក្នុងច្បាប់ដទៃទៀតរបស់រដ្ឋនោះ។

## មាត្រា ៤
## និវាសនជន

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ "និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង" សំដៅដល់បុគ្គលណាមួយ ដែលជាប់ពន្ធនៅក្រោមច្បាប់របស់រដ្ឋនោះ ដោយសារមានលំនៅដ្ឋាន និវាសនដ្ឋាន ទីកន្លែងចុះបញ្ជីរបស់ក្រុមហ៊ុន ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង ទីកន្លែងប្រកបអាជីវកម្មជាគោលដើម ឬលក្ខណវិនិច្ឆ័យផ្សេងទៀត ដែលមានភាពប្រហាក់ប្រហែល ដោយរួមបញ្ចូលផងដែរទាំងរដ្ឋនោះ និងអាជ្ញាធរមូលដ្ឋាននៃរដ្ឋនោះ។

២- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីដែលបុគ្គលម្នាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ស្ថានភាពរបស់បុគ្គលនោះ ត្រូវបានកំណត់ដូចខាងក្រោម÷

ក. បុគ្គលនោះត្រូវបានចាត់ទុកជានិវាសនជនរបស់រដ្ឋម្ខាងប៉ុណ្ណោះ ដែលបុគ្គលនោះមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ។ ប្រសិនបើបុគ្គលនោះមានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋទាំងពីរ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋមួយដែលមាន ទំនាក់ទំនងផ្ទាល់ខ្លួន និងសេដ្ឋកិច្ចជិតស្និទ្ធជាង (មូលដ្ឋានផលប្រយោជន៍សំខាន់)។

ខ. ប្រសិនបើពុំអាចកំណត់រដ្ឋដែលបុគ្គលនេះមានមូលដ្ឋានផលប្រយោជន៍សំខាន់ៗបាន ឬបុគ្គលនោះគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍សម្រាប់ស្នាក់នៅក្នុងរដ្ឋណាមួយ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាងដែលបុគ្គលនោះមានកន្លែងស្នាក់នៅជាទម្លាប់។

គ. ប្រសិនបើបុគ្គលនោះមាន ឬគ្មានកន្លែងស្នាក់នៅជាទម្លាប់នៅក្នុងរដ្ឋទាំងពីរ បុគ្គលនោះត្រូវចាត់ទុកជានិវាសនជនតែក្នុងរដ្ឋម្ខាង ដែលបុគ្គលនោះមានសញ្ជាតិ។

ឃ. ក្នុងករណីដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវដោះស្រាយបញ្ហាតាមរយៈការព្រមព្រៀងទៅវិញទៅមក។

៣- យោងតាមបញ្ញត្តិនៃកថាខណ្ឌ១ ក្នុងករណីបុគ្គលដែលមិនមែនជារូបវន្តបុគ្គល ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ត្រូវដោះស្រាយបញ្ហាតាមរយៈការព្រមព្រៀងទៅវិញទៅមក

## មាត្រា ៥
## គ្រឹះស្ថានអចិន្ត្រៃយ៍

១- សម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" សំដៅដល់ទីកន្លែងប្រកបអាជីវកម្មជាប់លាប់ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងធ្វើការប្រកបអាជីវកម្មទាំងស្រុង ឬផ្នែកណាមួយនៃអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

២- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" មានជាអាទិ៍÷

ក. ទីកន្លែងសម្រាប់ធ្វើការងារគ្រប់គ្រង

ខ. សាខារបស់សហគ្រាសបរទេស

គ. ការិយាល័យ

ឃ. រោងចក្រ

ង. រោងជាង

ច. ឃ្លាំង ឬបរិវេណដែលប្រើប្រាស់ជាកន្លែងលក់

ឆ. កសិដ្ឋាន ឬកន្លែងដាំដុះ និង

ជ. ទីតាំងរុករករ៉ែ អណ្តូងប្រេងកាត ឬឧស្ម័នធម្មជាតិ ទីតាំងវាយយកថ្ម ឬទីតាំងយក ឬស្វែងរុករក ឬធ្វើអាជីវកម្មធនធានធម្មជាតិ ដែលរួមបញ្ចូលផលិតផលពីឈើ ឬព្រៃឈើ ការបង្កុំ រចនាសម្ព័ន្ធ គ្រឿងចក្រសម្រាប់ខួងអណ្តូងប្រេងកាត នាវាសម្រាប់ផ្គត់ផ្គង់ដែលប្រើសម្រាប់ស្វែងរុករក ឬធ្វើអាជីវកម្មធនធានធម្មជាតិ។

៣- ពាក្យ "គ្រឹះស្ថានអចិន្ត្រៃយ៍" ក៏រួមបញ្ចូលផងដែរ÷

ក. ការដ្ឋានសំណង់អគារ គម្រោងសាងសង់ឬគម្រោងបង្គុំឬដំឡើង ឬសកម្មភាពតាមដានពិនិត្យ ដែលជាប់ទាក់ទិននឹងទីតាំងឬគម្រោងទាំងនោះ ក៏ប៉ុន្តែលុះត្រាការដ្ឋាន ឬគម្រោង ឬសកម្មភាពទាំងនោះ មានរយៈពេលលើសពី ១៨៣ថ្ងៃ។

ខ. ការផ្តល់សេវា ដែលរួមមានទាំងសេវាប្រឹក្សាដែលធ្វើឡើងដោយសហគ្រាសតាមរយៈនិយោជិត ឬបុគ្គលិកផ្សេងទៀតជួលដោយសហគ្រាសនោះ ក្នុងគោលដៅខាងលើ លុះត្រាតែសកម្មភាពទាំងនោះបានប្រព្រឹត្តទៅជាបន្តបន្ទាប់ (សម្រាប់គម្រោងដូចគ្នា

ឬពាក់ព័ន្ធគ្នា) នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ១៨៣ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ ។

គ. សកម្មភាពអាជីវកម្ម (រួមបញ្ចូលទាំងប្រតិបត្តិការឧបករណ៍ធុនធ្ងន់) នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតសម្រាប់ការស្វែងរុករក ឬការធ្វើអាជីវកម្មធនធានធម្មជាតិ សម្រាប់មួយលើក ឬច្រើនលើក ដែលមានរយៈពេលសរុបលើសពី ៩០ថ្ងៃ ក្នុងអំឡុងពេល ១២ខែ ណាមួយ។

៤ ទោះបីជាមានបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ ពាក្យ"គ្រឹះស្ថានអចិន្ត្រៃយ៍" មិនត្រូវបានចាត់ទុកថារាប់បញ្ចូល÷

ក. ការប្រើប្រាស់នូវទីតាំងសម្រាប់តែគោលដៅក្នុងការស្តុកទុក ឬការតាំងបង្ហាញទំនិញ ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស

ខ. ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការស្តុកទុក ឬការតាំងបង្ហាញ

គ. ការថែទាំទំនិញក្នុងស្តុក ឬផលិតផល ដែលជាកម្មសិទ្ធិរបស់សហគ្រាស សម្រាប់តែគោលដៅក្នុងការកែច្នៃដោយសហគ្រាសដទៃទៀត

ឃ. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅក្នុងការទិញទំនិញ ឬផលិតផល ឬការប្រមូលព័ត៌មានសម្រាប់សហគ្រាស

ង. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែគោលដៅនៃការផ្សព្វផ្សាយពាណិជ្ជកម្ម ការផ្តល់ព័ត៌មាន ដែលមានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ សម្រាប់សហគ្រាស

ច. ការរក្សាទីកន្លែងប្រកបអាជីវកម្មជាប់លាប់ សម្រាប់តែសកម្មភាពរួមផ្សំគ្នាណាមួយនៃសកម្មភាពដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ង)

ក្នុងលក្ខខណ្ឌដែលសកម្មភាពនេះ ឬក្នុងករណីវាក្យខណ្ឌ (ច) ដែលជាសកម្មភាពរួមនៃទីកន្លែងប្រកបអាជីវកម្មជាប់លាប់ មានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ។

៥-	កថាខណ្ឌ៤ ពុំត្រូវអនុវត្តចំពោះទីកន្លែងប្រកបអាជីវកម្មជាប់លាប់ដែលប្រើប្រាស់ ឬរក្សាដោយ សហគ្រាស ក្នុងករណីដែលសហគ្រាសនោះ ឬសហគ្រាសដែលមានទំនាក់ទំនងជិតស្និទ្ធប្រកបសកម្មភាពអាជីវកម្មនៅទីតាំងដូចគ្នាឬផ្សេងគ្នា នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងតែមួយ និង

ក. ទីកន្លែងនោះ ឬទីកន្លែងផ្សេងទៀត បង្កើតជាគ្រឹះស្ថានអចិន្ត្រៃយ៍សម្រាប់សហគ្រាស ឬសហគ្រាសដែលមានទំនាក់ទំនងជិតស្និទ្ធ ដោយយោងតាមបញ្ញត្តិនៃមាត្រានេះ ឬ

ខ. សកម្មភាពរួមដែលកើតចេញពីការផ្សំគ្នារវាងសកម្មភាពអាជីវកម្មផ្សេងៗ ដែលធ្វើឡើងដោយសហគ្រាសពីរនៅកន្លែងតែមួយ ឬដោយសហគ្រាសនោះផ្ទាល់ ឬដោយសហគ្រាសដែលមានទំនាក់ទំនងជិតស្និទ្ធនៅទីកន្លែងពីរផ្សេងគ្នា ហើយដែលសកម្មភាពរួមនោះពុំមានចរិតលក្ខណៈត្រៀមបម្រុងទុក ឬបន្ទាប់បន្សំ

ក្នុងលក្ខខណ្ឌដែលសកម្មភាពអាជីវកម្មទាំងនោះ ត្រូវបានធ្វើឡើងដោយសហគ្រាសពីរនៅកន្លែងតែមួយ ឬដោយសហគ្រាសនោះផ្ទាល់ ឬដោយសហគ្រាសដែលមានទំនាក់ទំនងជិតស្និទ្ធនៅទីកន្លែងពីរផ្សេងគ្នា បង្កើតជាមុខងារបំពេញបន្ថែម ដែលជាផ្នែកមួយនៃប្រតិបត្តិការអាជីវកម្មមានលក្ខណៈពេញលេញ។

៦-	ទោះបីជាមានបញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ក៏ដោយ បុគ្គល (ក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យដែលកថាខណ្ឌ៧ អនុវត្ត) បំពេញសកម្មភាពនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងក្នុងនាមសហគ្រាសមួយនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សហគ្រាសនោះត្រូវបានចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍ក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងដែលបានលើកឡើងពីខាងដើម ចំពោះបណ្តាសកម្មភាពដែលធ្វើឡើងក្នុងនាមសហគ្រាស ក្នុងករណីដែលបុគ្គលនោះ÷

ក. មាន និងអនុវត្តសិទ្ធិជាប្រចាំលើការចុះកិច្ចសន្យាក្នុងនាមសហគ្រាសនៅក្នុងរដ្ឋនោះ វៀរលែងតែសកម្មភាពទាំងនោះ ត្រូវបានកំណត់ដូចមានចែងក្នុងកថាខណ្ឌ៤ខាងលើ ទោះបីសកម្មភាពនោះធ្វើឡើងតាមរយៈទីកន្លែងប្រកបអាជីវកម្មជាប់លាប់ក៏ដោយ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នោះ មិនត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអចិន្ត្រៃយ៍ក្រោមបញ្ញត្តិនៃកថាខណ្ឌ៤ នោះឡើយ ឬ

ខ. ពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យា ប៉ុន្តែ ថែរក្សាស្តុកទំនិញឬផលិតផលជាប្រចាំនៅក្នុងរដ្ឋខាងដើម ដែលតែងតែបញ្ជូនទំនិញ ឬផលិតផលក្នុងនាមសហគ្រាសជាទៀងទាត់។

គ. ពុំមានសិទ្ធិក្នុងការចុះកិច្ចសន្យា ប៉ុន្តែធានាការបញ្ជាទិញទាំងស្រុង ឬស្ទើរតែទាំងស្រុង ជាប្រចាំនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងខាងដើម ឱ្យសហគ្រាសផ្ទាល់ ឬឱ្យសហគ្រាសនោះ និងសហគ្រាសដទៃទៀតដែលត្រូវបានគ្រប់គ្រងដោយសហគ្រាសនោះ ឬមានសិទ្ធិគ្រប់គ្រងលើសហគ្រាសនោះ ឬ

ឃ. ផលិត ឬកែច្នៃទំនិញដែលជារបស់សហគ្រាសនោះនៅក្នុងរដ្ឋខាងដើម។

៧- ក. សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មិនត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដោយគ្រាន់តែប្រកបអាជីវកម្មក្នុងរដ្ឋម្ខាងទៀតនោះ តាមរយៈឈ្មួញកណ្ដាល ភ្នាក់ងារកម្រៃជើងសារទូទៅ ឬភ្នាក់ងារដទៃទៀតដែលមានលក្ខណៈឯករាជ្យក្នុងលក្ខខណ្ឌដែលបុគ្គលទាំងនោះ បំពេញសកម្មភាពដែលជាដំណើរការប្រក្រតីនៃអាជីវកម្មរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីភ្នាក់ងារនោះធ្វើសកម្មភាពទាំងស្រុង ឬស្ទើរតែទាំងស្រុងក្នុងនាមសហគ្រាសមួយ ឬសហគ្រាសច្រើនដែលមានទំនាក់ទំនងជិតស្និទ្ធ រួមបញ្ចូលទាំងទំនាក់ទំនងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ភ្នាក់ងារនោះ មិនត្រូវបានចាត់ទុកថាជាភ្នាក់ងារដែលមានលក្ខណៈឯករាជ្យ ក្នុងន័យនៃកថាខណ្ឌ នេះទេ។

ខ. សម្រាប់គោលដៅនៃមាត្រានេះ បុគ្គលម្នាក់មានទំនាក់ទំនងជិតស្និទ្ធទៅនឹងសហគ្រាសមួយ ក្នុងករណីដែលបុគ្គលគ្រប់គ្រងសហគ្រាសឬសហគ្រាសគ្រប់គ្រងបុគ្គល ឬបុគ្គល និងសហគ្រាសនោះ ស្ថិតក្រោមការគ្រប់គ្រងតែមួយដោយបុគ្គល ឬសហគ្រាសផ្សេងទៀត ដោយផ្អែកលើភាពជាក់ស្ដែង និងកាលៈទេសៈពាក់ព័ន្ធទាំងអស់។ ក្នុងករណីណាក៏ដោយ បុគ្គលម្នាក់ត្រូវចាត់ទុកថាមានទំនាក់ទំនងជិតស្និទ្ធទៅនឹងសហគ្រាសមួយ ប្រសិនបើបុគ្គលនោះកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥០ ភាគរយនៃសិទ្ធិដែលទទួលបានផលប្រយោជន៍ក្នុងសហគ្រាសនោះ (ឬក្នុងករណីក្រុមហ៊ុន សំដៅដល់ចំនួនលើសពី ៥០ ភាគរយ នៃសំឡេងឆ្នោតសរុប និងតម្លៃនៃភាគហ៊ុន ឬសិទ្ធិដែលទទួលបានផលប្រយោជន៍នៃទ្រព្យសកម្មសុទ្ធក្នុងក្រុមហ៊ុន) ឬក្នុងករណីបុគ្គលដទៃទៀតកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥០ ភាគរយ នៃសិទ្ធិដែលទទួលបានផលប្រយោជន៍ (ឬក្នុងករណីក្រុមហ៊ុន សំដៅដល់ចំនួនលើសពី ៥០ ភាគរយ

នៃសំឡេងឆ្នោតសរុប និងតម្លៃនៃភាគហ៊ុន ឬសិទ្ធិដែលទទួលបានផលប្រយោជន៍នៃទ្រព្យសកម្មសុទ្ធក្នុងក្រុមហ៊ុន) ពីបុគ្គល និងសហគ្រាសនោះ។

៨- ទោះបីជាមានបញ្ញត្តិខាងដើមនៃមាត្រានេះក៏ដោយ វៀរលែងតែពាក់ព័ន្ធនឹងការធានារ៉ាប់រងបន្ត សហគ្រាសធានារ៉ាប់រងនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវចាត់ទុកថាមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប្រសិនបើសហគ្រាសនោះ ប្រមូលបុព្វលាភនៅក្នុងទឹកដីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ឬធានារ៉ាប់រងហានិភ័យផ្សេងៗ ដែលស្ថិតនៅក្នុងទឹកដីនៃរដ្ឋនោះ តាមរយៈបុគ្គលក្រៅពីភ្នាក់ងារមានលក្ខណៈឯករាជ្យដែលអនុវត្តតាមកថាខណ្ឌ៧។

៩- ក្នុងករណីដែលក្រុមហ៊ុនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងគ្រប់គ្រង ឬត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬដែលប្រកបអាជីវកម្មនៅក្នុងរដ្ឋម្ខាងទៀតនោះ (ទោះបីជាតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមិនមែនតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍) មិនត្រូវចាត់ទុកក្រុមហ៊ុនណាមួយ ជាគ្រឹះស្ថានអចិន្ត្រៃយ៍នៃក្រុមហ៊ុនណាមួយទៀតឡើយ។

## មាត្រា ៦
## ប្រាក់ចំណូលពីអចលនទ្រព្យ

១- ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងពីអចលនទ្រព្យ (រួមបញ្ចូលទាំងប្រាក់ចំណូលពីកសិកម្ម ឬរុក្ខាប្រមាញ់) ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ពាក្យ "អចលនទ្រព្យ" ត្រូវមានន័យដូចមានចែងក្នុងច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលអចលនទ្រព្យនោះស្ថិតនៅ។ ប៉ុន្តែសម្រាប់គោលដៅនៃកិច្ចព្រមព្រៀងនេះ ទោះក្នុងករណីណាក៏ដោយ ពាក្យនេះត្រូវរួមបញ្ចូលផងដែរនូវទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យ បសុសត្វនិងឧបករណ៍ប្រើប្រាស់នៅក្នុងកសិកម្ម និងរុក្ខាប្រមាញ់ សិទ្ធិដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ទូទៅ ដែលទាក់ទិននឹងទ្រព្យសម្បត្តិដែលបង្កើតចំណូល សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើអចលនទ្រព្យ និងសិទ្ធិទទួល បានការទូទាត់ក្នុងចំនួនជាក់លាក់ ឬប្រែប្រួលតាមលទ្ធផលជាក់ស្តែងសម្រាប់ការប្រកបអាជីវកម្ម ឬសិទ្ធិប្រកបអាជីវកម្មលើជម្រករ៉ែ ប្រភពធនធានរ៉ែ និងធនធានធម្មជាតិផ្សេងទៀត រួមបញ្ចូលឈើហុប និងផលិតផលព្រៃឈើផ្សេងទៀត។ នាវា និងយន្តហោះ មិនត្រូវចាត់ទុកជាអចលនទ្រព្យឡើយ។

៣- បញ្ញត្តិក្នុងកថាខណ្ឌ១ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលដែលទទួលបានពីការប្រើប្រាស់ផ្ទាល់ ការជួល ឬការប្រើប្រាស់ក្នុងរូបភាពផ្សេងទៀតនៃអចលនទ្រព្យ។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង៣ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណូលពីអចលនទ្រព្យរបស់សហគ្រាស និងចំពោះប្រាក់ចំណូលពីអចលនទ្រព្យដែលបានប្រើប្រាស់សម្រាប់បំពេញសេវាបុគ្គលឯករាជ្យ។

## មាត្រា ៧

## ប្រាក់ចំណេញអាជីវកម្ម

១- ប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវជាប់ពន្ធតែក្នុងរដ្ឋនោះប៉ុណ្ណោះ វៀរលែងតែសហគ្រាសនោះ ប្រកបអាជីវកម្មក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិ-ន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ។

ក្នុងករណីដែលសហគ្រាសនោះប្រកបអាជីវកម្មដូចបានរៀបរាប់ខាងលើ ប្រាក់ចំណេញរបស់សហគ្រាសអាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ លើតែប្រាក់ចំណេញណាដែលសម្រេចបានពី÷

ក- គ្រឹះស្ថានអចិន្ត្រៃយ៍នោះ

ខ- ការលក់ផលិតផលឬទំនិញ ដែលមានប្រភេទដូចគ្នាឬប្រហាក់ប្រហែលគ្នា ទៅនឹងផលិតផលដែលលក់តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងរដ្ឋម្ខាងទៀតនោះ ឬ

គ- សកម្មភាពអាជីវកម្មផ្សេងទៀត ដែលមានប្រភេទដូចគ្នាឬប្រហាក់ប្រហែលគ្នា ទៅនឹងសកម្មភាពរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ នៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- សម្រាប់គោលដៅបញ្ញត្តិនៃកថាខណ្ឌ៣ ក្នុងករណីសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅក្នុងរដ្ឋម្ខាងទៀតនោះ ប្រាក់ចំណេញដែលកើតពីគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ ត្រូវបានកំណត់ដូចប្រាក់ចំណេញនៃសហគ្រាសផ្សេងទៀត និងដាច់ដោយឡែកពីគ្នា ដែលមានសកម្មភាពអាជីវកម្មដូច ឬប្រហាក់ប្រហែលគ្នា ក្រោមលក្ខខណ្ឌដូច ឬប្រហាក់ប្រហែលគ្នា ដែលមានសកម្មភាពអាជីវកម្មឯករាជ្យទាំងស្រុងពីសហគ្រាសដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នោះ។

៣- ក្នុងការកំណត់ប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវអនុញ្ញាតឱ្យកាត់កងរាល់ចំណាយទាំងអស់ ដែលកើតឡើងសម្រាប់គោលបំណងអាជីវកម្មរបស់គ្រឹះស្ថានអចិន្ត្រៃយ៍នោះ រួមបញ្ចូលទាំងចំណាយសម្រាប់ប្រតិបត្តិការ និងរដ្ឋបាលទូទៅដែលកើតនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ស្ថិតនៅ ឬនៅកន្លែងផ្សេងទៀត។ ប៉ុន្តែការកាត់កងនេះមិនត្រូវបានអនុញ្ញាតចំពោះទឹកប្រាក់ (ក្រៅពីសំណងនៃចំណាយជាក់ស្តែង) ដែលទូទាត់ ដោយគ្រឹះស្ថានអចិន្ត្រៃយ៍ទៅទីស្នាក់ការកណ្តាល ឬការិយាល័យណាមួយផ្សេងទៀតរបស់សហគ្រាសក្រោមរូបភាពជាសួយសារ កម្រៃ ឬការទូទាត់

ប្រហាក់ប្រហែលផ្សេងទៀត ដើម្បីទទួលបានការប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម ឬសិទ្ធិផ្សេងទៀត ឬក្រោមរូបភាពជាកម្រៃជើងសារ សម្រាប់ការបំពេញសេវាកម្មជាក់លាក់ ឬ ការគ្រប់គ្រង ឬក្រោមរូបភាពជាការប្រាក់នៃកម្ចីដែលបានផ្តល់ឱ្យគ្រឹះស្ថានអចិន្ត្រៃយ៍ វៀរលែងតែក្នុងករណីសហគ្រាសធនាគារ។ ដូចគ្នានេះដែរ ការកំណត់ប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ មិនត្រូវអនុញ្ញាតឱ្យគិតបញ្ចូលនូវទឹកប្រាក់ (ក្រៅពីសំណងនៃចំណាយជាក់ស្តែង) ដែលគ្រឹះស្ថានអចិន្ត្រៃយ៍កំណត់យកពីទីស្នាក់ការកណ្តាល ឬការិយាល័យណាមួយផ្សេងទៀតរបស់សហគ្រាសក្រោមរូបភាពជាសួយសារ កម្រៃ ឬការទូទាត់ប្រហាក់ប្រហែលផ្សេងទៀត ដើម្បីទទួលបានការប្រើប្រាស់ប្រកាសនីយបត្រតក្កកម្ម ឬសិទ្ធិផ្សេងទៀត ឬក្រោមរូបភាពជាកម្រៃជើងសារ សម្រាប់ការបំពេញសេវាកម្មជាក់លាក់ ឬការគ្រប់គ្រង ឬក្រោមរូបភាពជាការប្រាក់នៃកម្ចីដែល បានផ្តល់ឱ្យទីស្នាក់ការកណ្តាល ឬការិយាល័យណាមួយផ្សេងទៀតរបស់សហគ្រាស វៀរលែងតែ ក្នុងករណីសហគ្រាសធនាគារ។

៤- ដរាបណារដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មានទម្លាប់ក្នុងការកំណត់ប្រាក់ចំណេញសម្រេចបានពីគ្រឹះស្ថានអចិន្ត្រៃយ៍ ដោយវិធីបែងចែកប្រាក់ចំណេញសរុបទៅតាមផ្នែកផ្សេងៗរបស់សហគ្រាស កថាខណ្ឌ២ មិនត្រូវរារាំងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះក្នុងការកំណត់ប្រាក់ចំណេញដែលត្រូវជាប់ពន្ធ តាមវិធីនៃការបែងចែកដែលជាទម្លាប់នេះ។ ការអនុវត្តវិធីនៃការបែងចែកនេះត្រូវផ្តល់លទ្ធផលដែលសមស្របទៅនឹងគោលការណ៍ក្នុងមាត្រានេះ។

៥- សម្រាប់គោលដៅនៃបណ្តាកថាខណ្ឌខាងលើនេះ ការកំណត់ប្រាក់ចំណេញដែលសម្រេចបានដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ត្រូវប្រើប្រាស់វិធាន ដូចគ្នាពីមួយឆ្នាំទៅមួយឆ្នាំ។ ការអនុវត្តផ្ទុយពីនេះ អាចប្រព្រឹត្តទៅបាន លុះត្រាតែមានហេតុផលសមរម្យ និងគ្រប់គ្រាន់។

៦- ក្នុងករណីដែលប្រាក់ចំណេញរួមបញ្ចូលទាំងប្រភេទប្រាក់ចំណូលផ្សេងៗ ដែលបានចែងដាច់ដោយឡែកនៅក្នុងមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ បញ្ញត្តិរបស់មាត្រាទាំងនោះមិនត្រូវបានគ្រប់ដណ្តប់ ដោយបញ្ញត្តិនៃមាត្រានេះទេ។

## មាត្រា ៨
## ការដឹកជញ្ជូនតាមនាវា និងយន្តហោះ

១- ប្រាក់ចំណេញដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ពីប្រតិបត្តិការនៃយន្តហោះក្នុងចរាចរណ៍អន្តរជាតិ ត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះតែប៉ុណ្ណោះ។

២- ប្រាក់ចំណេញពីប្រភពផ្សេងៗនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលទទួលបានដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ពីប្រតិបត្តិការនៃនាវាក្នុងចរាចរណ៍អន្តរជាតិ អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីខាងដើម ប៉ុន្តែការកំណត់ពន្ធនៅក្នុងរដ្ឋនោះ ត្រូវកាត់បន្ថយ ៥០ ភាគរយ។

៣- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ ត្រូវអនុវត្តផងដែរចំពោះប្រាក់ចំណេញពីការចូលរួមជាក្រុម ឬចង្កោមអាជីវកម្មរួមគ្នា ឬទីភ្នាក់ងារប្រតិបត្តិការអន្តរជាតិ។

## មាត្រា ៩
## សហគ្រាសដែលមានការទាក់ទងគ្នា

១- ក្នុងករណី÷

ក. សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់ចែង ការគ្រប់គ្រង ឬមានដើមទុននៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬ

ខ. បុគ្គលតែមួយ ចូលរួមដោយផ្ទាល់ ឬដោយប្រយោលក្នុងការចាត់ចែង ការគ្រប់គ្រង ឬមានដើមទុននៅក្នុងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត

ហើយនៅក្នុងករណីមួយណាក៏ដោយ លក្ខខណ្ឌត្រូវបានធ្វើឡើង ឬកំណត់ រវាងសហគ្រាសទាំងពីរនៅក្នុងទំនាក់ទំនងផ្នែកពាណិជ្ជកម្ម ឬផ្នែកហិរញ្ញវត្ថុ ដែលខុសគ្នាពីលក្ខខណ្ឌ ដែលត្រូវបានធ្វើឡើងរវាងបណ្តាសហគ្រាសឯករាជ្យ ដូចនេះ ប្រាក់ចំណេញដែលអាចត្រូវបង្គរដោយសហគ្រាសណាមួយនៅក្នុងចំណោមសហគ្រាស ដែលមានទំនាក់ទំនងទាំងនោះ ប៉ុន្តែពុំត្រូវបង្គរជាប្រាក់ចំណេញដោយហេតុផលនៃបណ្តាលក្ខខណ្ឌខាងលើ ប្រាក់ចំណេញនោះក៏អាចត្រូវរាប់បញ្ចូលជាប្រាក់ចំណេញរបស់សហគ្រាសនោះ និងត្រូវជាប់ពន្ធស្របតាមនីតិវិធីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង។

២- ក្នុងករណីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងរាប់បញ្ចូលប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតទៅក្នុងប្រាក់ចំណេញរបស់សហគ្រាសនៃរដ្ឋភាគីដំបូង ហើយបានយកពន្ធទៅតាមនីតិវិធីជាធរមាន ដែលប្រាក់ចំណេញដែលបានរាប់បញ្ចូលនោះ ត្រូវបានយកពន្ធរួចហើយដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ហើយប្រាក់ចំណេញដែលដាក់បញ្ចូលនោះគឺជាប្រាក់ចំណេញដែលគួរត្រូវបានទទួលដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងដំបូងប្រសិនបើលក្ខខណ្ឌដែលបានធ្វើឡើងរវាងសហគ្រាសទាំងពីរនេះ ដូចលក្ខខណ្ឌដែលបានធ្វើរវាងសហគ្រាសឯករាជ្យ ដូចនេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតត្រូវធ្វើនិយ័តកម្មឱ្យសមស្របចំពោះប្រាក់ពន្ធដែលជាប្រាក់ចំណេញរបស់ខ្លួន។ ក្នុងការកំណត់និយ័តកម្មនេះ បញ្ញត្តិពាក់ព័ន្ធដទៃទៀតនៃកិច្ចព្រមព្រៀងត្រូវអនុវត្តជាចាំបាច់ ហើយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរត្រូវធ្វើការពិភាក្សាគ្នា ប្រសិនបើមានការចាំបាច់។

៣- ក្នុងករណីដែលដំណើរការនីតិវិធីតុលាការ បែបបទរដ្ឋបាល ឬដំណើរការនីតិវិធីផ្លូវច្បាប់ផ្សេងទៀតដែលនាំឱ្យមានការសម្រេចជាស្ថាពរថា ដោយបុព្វហេតុនៃសកម្មភាពនានា ដែលបណ្តាលឱ្យមាននិយ័តកម្ម លើប្រាក់ចំណេញក្រោមបញ្ញត្តិនៃកថាខណ្ឌ១ ចំពោះសហគ្រាសដែលទាក់ទិននឹងទោសទណ្ឌដោយការក្លែងបន្លំ ការធ្វេសប្រហែសធ្ងន់ធ្ងរ ឬដោយចេតនា បញ្ញត្តិនៃកថាខណ្ឌ២ មិនត្រូវយកមកអនុវត្ត។

## មាត្រា ១០

## ភាគលាភ

១- ភាគលាភដែលត្រូវបានទូទាត់ដោយក្រុមហ៊ុននិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឱ្យទៅនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធក្នុងរដ្ឋម្ខាងទៀតនោះ។

២- ភាគលាភនោះក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលក្រុមហ៊ុនទូទាត់ភាគលាភនោះ ជានិវាសនជនផងដែរ ដោយអនុលោមទៅតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃភាគលាភនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវលើសពី ១០ភាគរយ នៃចំនួនដុល នៃភាគលាភ។ កថាខណ្ឌនេះមិនប៉ះពាល់ដល់ការយកពន្ធលើក្រុមហ៊ុនចំពោះប្រាក់ចំណេញដែលជាប្រភពនៃភាគលាភដែលបានទូទាត់។

៣- ពាក្យ "ភាគលាភ" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ប្រាក់ចំណូលដែលបានមកពីភាគហ៊ុននានា ឬសិទ្ធិផ្សេងៗដែលមិនមែនជាឥណទេយ្យបំណុល ប៉ុន្តែចូលរួមទទួលប្រាក់ចំណេញ ក៏ដូចជាចំណូលបានមកពីសិទ្ធិក្នុងក្រុមហ៊ុន ដែលត្រូវបានកំណត់ពន្ធដូចគ្នាទៅនឹងប្រាក់ចំណូលបានពីភាគហ៊ុន ដែលកំណត់ដោយច្បាប់នៃរដ្ឋដែលក្រុមហ៊ុនបែងចែកភាគលាភនោះជានិវាសនជន។

៤- បញ្ញត្តិក្នុងកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃភាគលាភជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលក្រុមហ៊ុនទូទាត់ភាគលាភជានិវាសនជន តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- គ្មានបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយក្នុងការរារាំងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងពីការកំណត់ពន្ធលើការដកប្រាក់ចំណេញរបស់គ្រឹះស្ថានអចិន្ត្រៃយ៍ចេញពីរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះដោយអនុលោមទៅតាមបទប្បញ្ញត្តិនានានៃច្បាប់ក្នុងស្រុក។ ប៉ុន្តែពន្ធដែលបានកំណត់ មិនត្រូវលើសពីអត្រាដែលបានបញ្ជាក់ក្នុងកថាខណ្ឌ២ នៃមាត្រានេះ។

៦-	ក្នុងករណីក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទទួលប្រាក់ចំណេញ ឬប្រាក់ចំណូលមកពីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត រដ្ឋម្ខាងទៀតនោះ អាចមិនត្រូវកំណត់ពន្ធទៅលើភាគលាភដែលបានទូទាត់ដោយក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដំបូងនោះទេ លើកលែងតែភាគលាភទាំងនោះត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋម្ខាងទៀត ឬការកាន់កាប់ភាគហ៊ុនដែលនាំឱ្យមានការទូទាត់ភាគលាភនោះ មានទំនាក់ទំនងជាក់លាក់ជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ។ ដូចនេះ ប្រាក់ចំណេញដែលមិនបានបែងចែករបស់ក្រុមហ៊ុនដែលជានិវាសនជននៃរដ្ឋភាគីដំបូង មិនគួរជាកម្មវត្ថុនៃការកំណត់ពន្ធលើប្រាក់ចំណេញមិនបានបែងចែករបស់ក្រុមហ៊ុន ដោយរដ្ឋម្ខាងទៀតនោះ ទោះបីជាភាគលាភដែលបានទូទាត់ ឬប្រាក់ចំណេញ មិនបានបែងចែក មានចំណែកខ្លះ ឬទាំងស្រុងពីប្រាក់ចំណេញ ឬប្រាក់ចំណូលដែលបានកើតឡើងក្នុងរដ្ឋម្ខាងទៀតនោះ ក៏ដោយ។

## មាត្រា ១១
## ការប្រាក់

១- ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ការប្រាក់នោះក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលការប្រាក់នោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់នោះជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃការប្រាក់នោះទេ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ២ ក៏ដោយ ការប្រាក់ដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងបានទូទាត់ទៅឱ្យរដ្ឋាភិបាល ឬអាជ្ញាធរមូលដ្ឋាន ធនាគារកណ្តាល ឬស្ថាប័នហិរញ្ញវត្ថុដទៃទៀតដែល ភាគហ៊ុន ១០០ ភាគរយ កាន់កាប់ដោយរដ្ឋាភិបាលនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវបានលើកលែងពន្ធនៅក្នុងរដ្ឋខាងដើម។

ក. សម្រាប់ឥណ្ឌូនេស៊ី÷

(i) ធនាគារឥណ្ឌូនេស៊ី (ធនាគារកណ្តាលនៃឥណ្ឌូនេស៊ី)

(ii) លេមបាហ្កា ពិមប៊ីយ៉ាយ៉ាន អេកស្ព័រ ឥណ្ឌូនេស៊ី (ធនាគារអ៊ិចស៊ិមនៃឥណ្ឌូនេស៊ី)

(iii) បាដាន ពេនយ៉េលេងហ្គារ៉ា ចាមីណាន សូស្យ៉ាល់ កេសេហាតាន (ទីភ្នាក់ងារសន្តិសង្គមសម្រាប់សុខភាពនៃឥណ្ឌូនេស៊ី)

(iv) បាដាន ពេនយ៉េលេងហ្គារ៉ា ចាមីណាន សូស្យ៉ាល់ កេតេនាហ្គកឹចាន (ទីភ្នាក់ងារសន្តិសង្គមសម្រាប់ពលករ)

(v) នីតិបុគ្គលសាធារណៈ និងស្ថាប័នដទៃទៀតដូចដែលអាចព្រមព្រៀងគ្នាទៅពេលក្រោយរវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

ខ. សម្រាប់កម្ពុជា÷

(i) ធនាគារកណ្តាល ឬអាជ្ញាធរមូលដ្ឋាន

(ii) ធនាគារអភិវឌ្ឍន៍ជនបទ

(iii) បេឡាជាតិរបបសន្តិសុខសង្គម និង

(iv) នីតិបុគ្គលសាធារណៈ

ឬស្ថាប័នដទៃទៀតដូចដែលអាចព្រមព្រៀងគ្នានាពេលក្រោយរវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ។

៤- ពាក្យ "ការប្រាក់" ដែលប្រើក្នុងមាត្រានេះសំដៅដល់ចំណូលពីបំណុលគ្រប់ប្រភេទ ទោះបីជាបានឬមិនបានធានាដោយការដាក់វត្ថុបញ្ចាំ និងមានឬគ្មានសិទ្ធិទទួលបានការបែងចែកប្រាក់ចំណេញរបស់កូនបំណុលនិងជាពិសេសចំណូលដែលបានមកពីមូលបត្ររដ្ឋ និងចំណូលដែលបានមកពីសញ្ញាប័ណ្ណ ឬមូលបត្របំណុល រួមបញ្ចូលផងដែរនូវបុព្វលាភ និងរង្វាន់ដែលភ្ជាប់ជាមួយនឹងមូលបត្ររដ្ឋ សញ្ញាប័ណ្ណ ឬមូលបត្របំណុលទាំងនោះ ក៏ដូចជាចំនួនទឹកប្រាក់នានាដទៃទៀតដែលត្រូវបានចាត់ទុកជាប្រាក់ចំណូលបានពីការឱ្យខ្ចីដូចដែលបានកំណត់នៅក្នុងច្បាប់ដែលពាក់ព័ន្ធនឹងពន្ធដារនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលប្រាក់ចំណូលកើតឡើង។ សម្រាប់គោលបំណងនៃមាត្រានេះ ប្រាក់ពិន័យដែលបានមកពីការបង់យឺតយ៉ាវ មិនត្រូវបានចាត់ទុកជាការប្រាក់ឡើយ។

៥- បញ្ញត្តិនៃកថាខណ្ឌ១ និង២ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃការប្រាក់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលការប្រាក់នោះកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យតាមរយៈមូលដ្ឋានជាប់លាប់ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងបំណុលដែលនាំឱ្យមានការទូទាត់ការប្រាក់នោះ មានទំនាក់ទំនងជាក់លាក់ជាមួយ ក) គ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ឬជាមួយ ខ) សកម្មភាពអាជីវកម្មដូចមានចែងក្នុងចំណុច គ) នៃកថាខណ្ឌ១ នៃមាត្រា៧។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៦- ការប្រាក់ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកទូទាត់ការប្រាក់គឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់ការប្រាក់ជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានការទាក់ទិននឹងបំណុលត្រូវបង់ការប្រាក់ ហើយការប្រាក់នោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះ

ការប្រាក់នោះ ត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ស្ថិតនៅ។

៧- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកទូទាត់ការប្រាក់និងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត ចំនួនការប្រាក់ដែលត្រូវទូទាត់ពាក់ព័ន្ធនឹងបំណុល មានចំនួនលើសពីចំនួនការប្រាក់ដែលបានព្រមព្រៀងរវាងអ្នកទូទាត់ការប្រាក់ និងម្ចាស់សិទ្ធិអាស្រ័យផលក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀង ក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀត នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១២
## ស្ងួយសារ

១- ស្ងួយសារដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទូទាត់ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ស្ងួយសារនោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលស្ងួយសារនោះកើតឡើងផងដែរនិងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃស្ងួយសារនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុលនៃស្ងួយសារនោះទេ។

៣- ពាក្យ "ស្ងួយសារ" ដែលប្រើក្នុងមាត្រានេះ សំដៅដល់ការទូទាត់ណាមួយជាសំណងសម្រាប់ការប្រើប្រាស់ឬសិទ្ធិប្រើប្រាស់សិទ្ធិអ្នកនិពន្ធនៃស្នាដៃអក្សរសាស្ត្រ ការងារសិល្បៈឬវិទ្យាសាស្ត្រ ដែលរួមមាន ខ្សែភាពយន្តឬភាពយន្ត ឬខ្សែអាត់ដែលប្រើសម្រាប់ការចាក់ផ្សាយតាមវិទ្យុឬទូរទស្សន៍ ប្រកាសនីយបត្រតក្កកម្ម ពាណិជ្ជសញ្ញា ការរចនាម៉ូដឬម៉ូដែល ប្លង់ រូបមន្តឬរបៀបធ្វើសម្ងាត់ ឬសម្រាប់ការប្រើប្រាស់ ឬសិទ្ធិប្រើប្រាស់បរិក្ខារឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ ឬសម្រាប់ព័ត៌មានដែលទាក់ទិននឹងបទពិសោធន៍ខាងឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិទ្យាសាស្ត្រ។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ មិនត្រូវយកមកអនុវត្ត ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃស្ងួយសារជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលស្ងួយសារកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងសិទ្ធិឬទ្រព្យដែលនាំឱ្យមានការទូទាត់ស្ងួយសារនោះ មានទំនាក់ទំនងជាក់លាក់ជាមួយ ក) គ្រឹះស្ថានអចិន្ត្រៃយ៍ ឬ មូលដ្ឋានជាប់លាប់ ឬជាមួយ ខ) សកម្មភាពអាជីវកម្មដូចមានចែងក្នុងចំណុច គ) នៃកថាខណ្ឌ១ នៃមាត្រា៧។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- ស្ហួយសារត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកបង់ សួយសារគឺជានិវាសនជននៃរដ្ឋនោះ។ ទោះបីបុគ្គលបង់សួយសារជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលមានការទាក់ទិននឹងបំណុលនៃសួយសារត្រូវបង់ ហើយសួយសារនោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ដូចនេះសួយសារនោះត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៦- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងអ្នកបង់សួយសារនិងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងអ្នកទាំងពីរនិងបុគ្គលដទៃទៀត ចំនួនសួយសារដែលត្រូវបង់ពាក់ព័ន្ធនឹងការប្រើប្រាស់សិទ្ធិ ឬព័ត៌មាន មានចំនួនលើសពីចំនួនសួយសារដែលបានព្រមព្រៀងរវាងអ្នកបង់សួយសារ និងម្ចាស់សិទ្ធិអាស្រ័យផល ក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ បញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀងក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៣
## កម្រៃសេវាបច្ចេកទេស

១- កម្រៃសេវាបច្ចេកទេសដែលកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ហើយត្រូវបានទទួល ដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- កម្រៃសេវាបច្ចេកទេសនោះ ក៏អាចជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលកម្រៃសេវាបច្ចេកទេសនោះកើតឡើងផងដែរ និងអនុលោមតាមច្បាប់នៃរដ្ឋនោះ ប៉ុន្តែប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេសជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត បន្ទុកពន្ធដែលត្រូវបង់មិនត្រូវឱ្យលើសពី ១០ ភាគរយ នៃចំនួនដុល នៃកម្រៃសេវាបច្ចេកទេស។

៣- ពាក្យ "កម្រៃសេវាបច្ចេកទេស" សំដៅដល់ការទូទាត់គ្រប់ប្រភេទជាសំណងសម្រាប់ការបំពេញសេវាគ្រប់គ្រង បច្ចេកទេស ឬពិគ្រោះយោបល់ រួមបញ្ចូលទាំងការផ្តល់សេវាកម្មដោយសហគ្រាស តាមរយៈបុគ្គលិកបច្ចេកទេស ឬបុគ្គលិកផ្សេងទៀត ប៉ុន្តែមិនរួមបញ្ចូលការទូទាត់លើសេវានានា ដែលមានចែងក្នុងមាត្រា១៦ នៃកិច្ចព្រមព្រៀងនេះ។

៤- បញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ មិនត្រូវអនុវត្តឡើយ ប្រសិនបើម្ចាស់សិទ្ធិអាស្រ័យផលនៃកម្រៃសេវាបច្ចេកទេសជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតដែលកម្រៃសេវាបច្ចេកទេសកើតឡើង តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ ហើយកម្រៃសេវាបច្ចេកទេសនោះ មានទំនាក់ទំនងជាក់លាក់ជាមួយ ក) គ្រឹះស្ថានអចិន្ត្រៃយ៍ ឬ មូលដ្ឋានជាប់លាប់ ឬជាមួយ ខ) សកម្មភាពអាជីវកម្មដូចមានចែងក្នុងចំណុច គ) នៃកថាខណ្ឌ១នៃមាត្រា៧។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៥- កម្រៃសេវាបច្ចេកទេសត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅពេលដែលអ្នកទូទាត់កម្រៃគឺជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ។ ទោះបីបុគ្គលទូទាត់កម្រៃសេវាបច្ចេកទេសជានិវាសនជន ឬមិនមែនជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែមានគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង

ដែលមានការទាក់ទិននឹងកាតព្វកិច្ចទូទាត់កម្រៃសេវាបច្ចេកទេសដែលកើតឡើង ហើយកម្រៃសេវាបច្ចេកទេសនោះត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ទាំងនោះ ដូច្នេះកម្រៃសេវាបច្ចេកទេសនោះត្រូវបានចាត់ទុកថាកើតឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ ស្ថិតនៅ។

៦- ក្នុងករណី មានទំនាក់ទំនងពិសេសរវាងបុគ្គលទូទាត់កម្រៃសេវាបច្ចេកទេសនិងម្ចាស់សិទ្ធិអាស្រ័យផល ឬរវាងបុគ្គលទាំងពីរ និងបុគ្គលដទៃទៀត ទោះក្នុងហេតុផលណាក៏ដោយ កម្រៃសេវាបច្ចេកទេសដែលត្រូវទូទាត់ មានចំនួនលើសពីកម្រៃសេវាបច្ចេកទេស ដែលគួរតែបានព្រមព្រៀងរវាងបុគ្គលទូទាត់ និងម្ចាស់សិទ្ធិអាស្រ័យផលក្នុងករណីពុំមានទំនាក់ទំនងពិសេសបែបនោះ ដូចនេះបញ្ញត្តិនៃមាត្រានេះ ត្រូវអនុវត្តចំពោះតែចំនួនទឹកប្រាក់ដែលភាគីទាំងពីរព្រមព្រៀង ក្នុងករណីពុំមានទំនាក់ទំនងពិសេសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំណែកលើសនៃការទូទាត់ ត្រូវជាប់ពន្ធស្របទៅតាមច្បាប់នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ និងអនុលោមតាមបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៤
## ចំណេញមូលធន

១- ចំណេញមូលធន ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរអចលនទ្រព្យ ដូចមានចែងក្នុងមាត្រា៦ ហើយដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ដែលជាចំណែកនៃទ្រព្យអាជីវកម្មរបស់គ្រឹះស្ថានអចិ-ន្ត្រៃយ៍ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ឬចំណេញមូលធនពីការលក់ឬផ្ទេរចលនទ្រព្យ ជាប់ទាក់ទិននឹងមូលដ្ឋានជាប់លាប់របស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត សម្រាប់គោលដៅនៃការបំពេញសេវាបុគ្គលឯករាជ្យ រួមបញ្ចូលទាំងចំណេញមូលធនពីការលក់ឬផ្ទេរគ្រឹះស្ថានអចិន្ត្រៃយ៍ (គ្រឹះស្ថានអចិន្ត្រៃយ៍តែឯង ឬជាមួយសហគ្រាសទាំងមូល) ឬពីការលក់ឬផ្ទេរមូលដ្ឋានជាប់លាប់ អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

៣- ចំណេញមូលធនដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរនាវា ឬយន្តហោះដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិ ឬពីការលក ឬផ្ទេរចលនទ្រព្យដែលជាប់ទាក់ទិននឹងប្រតិបត្តិការនៃនាវា ឬយន្តហោះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះ តែប៉ុណ្ណោះ។

៤- ចំណេញមូលធនដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការលក់ឬផ្ទេរភាគហ៊ុនដែលលើសពី ៥០ ភាគរយ នៃតម្លៃភាគហ៊ុននោះ បានមកដោយផ្ទាល់ ឬដោយប្រយោលពីអចលនទ្រព្យ ដែលស្ថិតនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

៥- ចំណេញមូលធនពីការលក់ឬផ្ទេរទ្រព្យទាំងឡាយ ក្រៅពីទ្រព្យដូចមានចែងនៅក្នុងបណ្ដាកថាខណ្ឌខាងលើនៃមាត្រានេះ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលអ្នកលក់ឬផ្ទេរ ជានិវាសនជន។

## មាត្រា ១៥
## សេវាបុគ្គលឯករាជ្យ

១- តាមបញ្ញត្តិនៃមាត្រា១៣ ប្រាក់ចំណូលដែលទទួលបានដោយរូបវន្តបុគ្គលដែលជានិវាសនជន នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ពីការបំពេញសេវាវិជ្ជាជីវៈ ឬសកម្មភាពផ្សេងទៀតដែលមានចរិតលក្ខណៈឯករាជ្យ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ លើកលែងតែករណីដូចខាងក្រោម ដែលប្រាក់ចំណូលទាំងនោះ ក៏អាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតផងដែរ÷

ក. ប្រសិនបើរូបវន្តបុគ្គលនោះ មានមូលដ្ឋានជាប់លាប់ដែលគាត់ប្រើប្រាស់ជាប្រចាំនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ក្នុងគោលបំណងបំពេញសកម្មភាពរបស់គាត់។ ក្នុងករណីនេះ មានតែចំណូលដែលសម្រេចបានតាមរយៈមូលដ្ឋានជាប់លាប់នោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ឬ

ខ. ប្រសិនបើរូបវន្តបុគ្គលនោះ មានវត្តមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតសម្រាប់រយៈពេលមួយលើក ឬច្រើនលើក ស្មើ ឬលើសពីចំនួនសរុប ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយ ហើយក្នុងករណីនេះ មានតែចំណូលទទួលបានពីសកម្មភាព ដែលបានបំពេញនៅក្នុងរដ្ឋម្ខាងទៀតនោះប៉ុណ្ណោះ ដែលអាចត្រូវជាប់ពន្ធនៅរដ្ឋនោះ។

២- ពាក្យ "សេវាវិជ្ជាជីវៈ" រួមបញ្ចូលជាពិសេសសកម្មភាពឯករាជ្យខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ សិល្បៈ អប់រំ ឬបង្រៀន ព្រមទាំងសកម្មភាពឯករាជ្យរបស់គ្រូពេទ្យ មេធាវី វិស្វករ ស្ថាបត្យករ ទន្តពេទ្យ និងគណនេយ្យករ។

## មាត្រា ១៦
## សេវាបុគ្គលមិនឯករាជ្យ

១- សម្រាប់គោលដៅបញ្ញត្តិនៃមាត្រា១៧ មាត្រា១៩ និងមាត្រា២០ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារ ត្រូវជាប់ពន្ធតែក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ វៀរលែងតែការបំពេញការងារនោះ ធ្វើឡើងនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ ប្រសិនបើការបំពេញការងារនោះ ធ្វើឡើងនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត លាភការដែលទទួលបាន អាចត្រូវជាប់ពន្ធនៅរដ្ឋម្ខាងទៀតនោះ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ លាភការដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងការបំពេញការងារនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវជាប់ពន្ធតែក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដំបូងប៉ុណ្ណោះ ប្រសិនបើ÷

ក. អ្នកទទួលលាភការមានវត្តមាននៅក្នុងរដ្ឋម្ខាងទៀត មួយលើក ឬច្រើនលើកដែលសរុបមិនលើសពី ១៨៣ថ្ងៃ ក្នុងរយៈពេល ១២ខែ ណាមួយ និង

ខ. លាភការត្រូវបានបង់ដោយ ឬក្នុងនាមនិយោជកដែលមិនមែនជានិវាសនជននៃរដ្ឋម្ខាងទៀត និង

គ. លាភការមិនត្រូវបានរ៉ាប់រងដោយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់ដែលនិយោជកមាននៅរដ្ឋម្ខាងទៀត។

៣- ទោះបីជាមានបណ្ដាបញ្ញត្តិខាងលើនៃមាត្រានេះក៏ដោយ លាភការដែលទទួលបានក្នុងការបំពេញការងារនៅលើនាវា ឬយន្តហោះ ដែលប្រតិបត្តិការក្នុងចរាចរណ៍អន្តរជាតិ ដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋនោះ។

## មាត្រា ១៧
## កម្រៃរបស់អភិបាល

១- កម្រៃ និងការទូទាត់ប្រហាក់ប្រហែលផ្សេងទៀត របស់អភិបាលដែលជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសមាជិកនៃក្រុមប្រឹក្សាភិបាល ឬរចនាសម្ព័ន្ធប្រហាក់ប្រហែលរបស់ក្រុមហ៊ុន ដែលជានិវាសនជនរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅរដ្ឋម្ខាងទៀតនោះ។

២- ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលទទួលដោយនិវាសនជន នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ក្នុងនាមជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន ដែលជានិវាសនជននៃរដ្ឋភាគីម្ខាងទៀត ត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

## មាត្រា ១៨
## សិល្បករ និងកីឡាករ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា១៥ និងមាត្រា១៦ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានដោយនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ក្នុងនាមជាសិល្បករល្ខោន អ្នកសម្តែងភាពយន្ត សិល្បករតាមវិទ្យុឬទូរទស្សន៍ ឬតន្ត្រីករ ឬក្នុងនាមជាកីឡាករ តាមរយៈសកម្មភាពផ្ទាល់ខ្លួនរបស់និវាសនជននោះ ដែលធ្វើឡើងនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះ។

២- ក្នុងករណីដែលប្រាក់ចំណូលរបស់សិល្បករ/អ្នកសម្តែង ឬកីឡាករ សម្រេចបានតាមរយៈសកម្មភាពផ្ទាល់ខ្លួន ដែលប្រាក់ចំណូលនោះមិនបានបង្គរទុកនៅសិល្បករ/អ្នកសម្តែង ឬកីឡាករនោះផ្ទាល់ទេ ប៉ុន្តែត្រូវបានបង្គរទុកនៅបុគ្គលផ្សេងទៀត ដូចនេះប្រាក់ចំណូលនោះ អាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពរបស់សិល្បករ/អ្នកសម្តែង ឬកីឡាករនោះកើតឡើង ទោះបីជាមានបញ្ញត្តិនៃមាត្រា៧ មាត្រា១៥ និងមាត្រា១៦ ក៏ដោយ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ ក៏ដោយ ប្រាក់ចំណូលដែលទទួលបានពីសកម្មភាពដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ ដែលបានបំពេញក្រោមក្របខ័ណ្ឌនៃកម្មវិធីផ្លាស់ប្តូរ វប្បធម៌ ឬកីឡាដែលបានព្រមព្រៀងរវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាង ត្រូវទទួលបានការលើកលែងពន្ធក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលសកម្មភាពទាំងនោះកើតឡើង។

## មាត្រា ១៩
## ប្រាក់សោធននិវត្តន៍ ធនលាភ និងការទូទាត់របបសន្តិសុខសង្គម

១- តាមបញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រា២០ ប្រាក់សោធននិវត្តន៍ ធនលាភ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ចំពោះការបំពេញការងារកន្លងមក អាចត្រូវជាប់ពន្ធតែនៅរដ្ឋម្ខាងនោះ។

២- ប្រាក់សោធននិវត្តន៍ ធនលាភ និងលាភការប្រហាក់ប្រហែលផ្សេងទៀតនោះ ក៏អាចត្រូវជាប់ពន្ធផងដែរនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ប្រសិនបើការទូទាត់នោះធ្វើឡើងដោយនិវាសនជន ឬគ្រឹះស្ថានអចិន្ត្រៃយ៍ដែលស្ថិតនៅរដ្ឋនោះ។

ពាក្យ "ធនលាភ" សំដៅដល់ចំនួនទឹកប្រាក់សរុបដែលត្រូវបង់ជាដំណាក់កាលទៀងទាត់ តាមពេលវេលាដែលបានកំណត់ក្នុងអំឡុងអាយុកាលនៃអ្នកទទួលធនលាភ ឬក្នុងរយៈពេលជាក់លាក់ដែលស្ថិតនៅក្រោមកាតព្វកិច្ចក្នុងការទូទាត់ដើម្បីទទួលបានជាសំណងនៃទឹកប្រាក់ ឬសំណងដែលមានតម្លៃស្មើ។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ ក៏ដោយ ប្រាក់សោធននិវត្តន៍ និងប្រាក់ទូទាត់ផ្សេងៗ ដែលត្រូវបានទូទាត់ក្រោមកម្មវិធីសាធារណៈ ឬកម្មវិធីដែលជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខសង្គម នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬអាជ្ញាធរមូលដ្ឋាន ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

## មាត្រា ២០
## ការបំពេញសេវាឱ្យរដ្ឋាភិបាល

១- ក. ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈនៃរដ្ឋភាគីម្ខាង ឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋ ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

ខ. ប៉ុន្តែ ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើសេវាត្រូវបានបំពេញនៅក្នុងរដ្ឋម្ខាងទៀតនោះ ដោយរូបវន្តបុគ្គលដែលជានិវាសនជននៃរដ្ឋនោះ÷

(i) ជាជនជាតិនៃរដ្ឋម្ខាងទៀតនោះ ឬ

(ii) មិនមែនជានិវាសនជនដោយគ្រាន់តែក្នុងគោលបំណងផ្តល់សេវាទាំងនោះតែប៉ុណ្ណោះ

២- ក. ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ ក៏ដោយ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ដែលបានទូទាត់ដោយ ឬទទួលបានពីមូលនិធិដែលបង្កើតដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាននៃរដ្ឋភាគីម្ខាងឱ្យទៅរូបវន្តបុគ្គលដែលបានបំពេញសេវាឱ្យរដ្ឋ ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋម្ខាងនោះប៉ុណ្ណោះ។

ខ- ប៉ុន្តែ ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀតខាងលើ ត្រូវជាប់ពន្ធតែនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតប៉ុណ្ណោះ ប្រសិនបើរូបវន្តបុគ្គលនោះគឺជានិវាសនជននិងជាជនជាតិនៃរដ្ឋនោះ។

៣- បញ្ញត្តិនៃមាត្រា១៦ មាត្រា១៧ មាត្រា១៨ និងមាត្រា១៩ ត្រូវយកមកអនុវត្តចំពោះប្រាក់បៀវត្ស ប្រាក់ឈ្នួល ប្រាក់សោធននិវត្តន៍ និងលាភការប្រហាក់ប្រហែលផ្សេងទៀត ចំពោះការបំពេញសេវា ដែលទាក់ទិននឹងការប្រកបអាជីវកម្មរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋាន ឬនីតិបុគ្គលសាធារណៈទាំងនោះ។

## មាត្រា ២១
## សិស្ស/និស្សិត និងអ្នកហាត់ការ

១- ការទូទាត់សម្រាប់ការទ្រទ្រង់ជីវភាព ឬអប់រំ ឬបណ្តុះបណ្តាលឱ្យសិស្ស/និស្សិត ឬអ្នកហាត់ការអាជីវកម្ម ឬកូនជាង ដែលជានិវាសនជន ឬថ្មីៗធ្លាប់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មុនពេលចេញទៅបំពេញការសិក្សានៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង និងមានវត្តមាននៅក្នុងរដ្ឋម្ខាងនោះ សម្រាប់តែគោលបំណងនៃការសិក្សាឬបណ្តុះបណ្តាល មិនត្រូវជាប់ពន្ធនៅក្នុងរដ្ឋនោះឡើយ ប្រសិនបើការទូទាត់មានប្រភពពីខាងក្រៅរដ្ឋនោះ។

២- ចំពោះជំនួយឥតសំណង អាហារូបករណ៍ និងលាភការពីការបំពេញការងារដែលមិនគ្របដណ្តប់ក្រោមវិសាលភាពនៃកថាខណ្ឌ១ សិស្ស/និស្សិត ឬអ្នកហាត់ការអាជីវកម្ម ឬកូនជាងដូចបានរៀបរាប់ក្នុងកថាខណ្ឌ១ ត្រូវទទួលបានបន្ថែមនូវការលើកលែង ការអនុគ្រោះ ឬការកាត់បន្ថយពន្ធទាំងឡាយដូចគ្នាជាមួយនឹងនិវាសនជននៃរដ្ឋដែលបុគ្គលនោះកំពុងស្នាក់នៅក្នុងអំឡុងពេលទទួលការអប់រំ និងវគ្គបណ្តុះបណ្តាល។

## មាត្រា ២២
## គ្រូបង្រៀន និងអ្នកស្រាវជ្រាវ

១- រូបវន្តបុគ្គលដែលជានិវាសនជន ឬថ្មីៗធ្លាប់ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មុនពេលចេញទៅបំពេញការងារនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត និងដោយទទួលការអញ្ជើញពីសាកលវិទ្យាល័យ មហាវិទ្យាល័យ សាលារៀន ឬស្ថាប័នអប់រំប្រហាក់ប្រហែលផ្សេងៗ ដែលបានទទួលស្គាល់ពីរដ្ឋាភិបាល សារៈមន្ទីរ ឬស្ថាប័នវប្បធម៌ផ្សេងទៀតក្នុងរដ្ឋម្ខាងទៀត និងមានវត្តមាននៅក្នុងរដ្ឋនោះរយៈពេលមិនលើសពី ២ឆ្នាំជាប់គ្នា សម្រាប់តែគោលបំណងបង្រៀន ឬធ្វើការស្រាវជ្រាវនៅតាមស្ថាប័នទាំងនោះ ត្រូវលើកលែងពន្ធក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ លើចំណូលពីសកម្មភាពខាងលើ។

២- បញ្ញត្តិនៃកថាខណ្ឌ១ មិនត្រូវយកមកអនុវត្ត ចំពោះប្រាក់ចំណូលដែលទទួលបានពីការស្រាវជ្រាវ ក្នុងករណីដែលការស្រាវជ្រាវនោះ ត្រូវបានធ្វើឡើងដោយរូបវន្តបុគ្គល សម្រាប់ផលប្រយោជន៍ឯកជនជាចម្បងរបស់បុគ្គលណាមួយ ឬបណ្តាបុគ្គលដទៃទៀត។

## មាត្រា ២៣
## ប្រាក់ចំណូលផ្សេងទៀត

១- ខ្ទង់ចំណូលរបស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀង ទោះកើតឡើងនៅកន្លែងណាក៏ដោយដែលមិនមានចែងនៅក្នុងបណ្តាមាត្រាទាំងឡាយខាងដើមនៃកិច្ចព្រមព្រៀងនេះ ត្រូវជាប់ពន្ធតែក្នុងរដ្ឋនោះប៉ុណ្ណោះ។

២- បញ្ញត្តិនៃកថាខណ្ឌ១ មិនត្រូវយកមកអនុវត្តចំពោះប្រាក់ចំណូលនានា ក្រៅពីប្រាក់ចំណូលបានពីអចលនទ្រព្យ ដូចបានកំណត់ក្នុងកថាខណ្ឌ២ នៃមាត្រា៦ ប្រសិនបើអ្នកទទួលប្រាក់ចំណូលនោះ ជានិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រកបអាជីវកម្មក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត តាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍ ឬបំពេញសេវាបុគ្គលឯករាជ្យ តាមរយៈមូលដ្ឋានជាប់លាប់ ដែលស្ថិតនៅរដ្ឋម្ខាងទៀតនោះ និងសិទ្ធិ ឬទ្រព្យដែលនាំឱ្យមានការទូទាត់ប្រាក់ចំណូលនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រឹះស្ថានអចិន្ត្រៃយ៍ ឬមូលដ្ឋានជាប់លាប់នោះ។ ចំពោះករណីនេះ បញ្ញត្តិនៃមាត្រា៧ ឬមាត្រា១៥ ត្រូវយកមកអនុវត្ត។

៣- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌ១ និង២ ក៏ដោយ ខ្ទង់ចំណូលរបស់និវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលមិនមានចែងនៅក្នុងបណ្តាមាត្រាទាំងឡាយខាងដើមនៃកិច្ចព្រមព្រៀងនេះ ហើយកើតឡើងក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត អាចត្រូវជាប់ពន្ធក្នុងរដ្ឋម្ខាងទៀតនោះ។

# មាត្រា ២៤

## ការលុបបំបាត់ការយកពន្ធត្រួតគ្នា

១- ក្នុងករណីនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទទួលបានប្រាក់ចំណូលដែលអាចត្រូវជាប់ពន្ធ នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ដោយអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងនោះ ត្រូវអនុញ្ញាតឱ្យកាត់កងពន្ធលើប្រាក់ចំណូលរបស់និវាសនជននោះនូវចំនួនប្រាក់ពន្ធស្មើ នឹងពន្ធលើប្រាក់ចំណូលដែលបានបង់នៅក្នុងរដ្ឋភាគីម្ខាងទៀតនោះ។ ប៉ុន្តែការកាត់កង មិនត្រូវឱ្យលើសពីចំណែកនៃប្រាក់ពន្ធលើប្រាក់ចំណូលដូចដែលបានគណនាមុនអនុញ្ញាតឱ្យមានការកាត់កង ដែលការអនុញ្ញាតនេះ គឺត្រឹមកម្រិតប្រាក់ចំណូលដែលអាចត្រូវជាប់ពន្ធនៅក្នុងរដ្ឋម្ខាងទៀតនោះតែប៉ុណ្ណោះ។

២- សម្រាប់គោលបំណងនៃការអនុញ្ញាតឱ្យមានការផ្តល់ជាឥណទាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ប្រាក់ពន្ធដែលបានបង់ក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវបានចាត់ទុកថារាប់បញ្ចូលនូវចំនួនប្រាក់ពន្ធដែលគួរតែបានបង់នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ ប៉ុន្តែត្រូវបានលើកលែង ឬកាត់បន្ថយ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានាទាក់ទិននឹងការលើកទឹកចិត្ត ដែលរៀបចំឡើងសំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងរដ្ឋម្ខាងទៀតនោះ។

៣- សម្រាប់គោលដៅនៃកថាខណ្ឌ១ នៃមាត្រានេះ សម្រាប់កម្ពុជា ពាក្យ "ប្រាក់ពន្ធដែលបានបង់" មិនត្រូវរាប់បញ្ចូលនូវពន្ធលើប្រាក់ចំណេញបន្ថែមលើការបែងចែកភាគលាភត្រូវបង់ទាក់ទិននឹងចំណូលដែលបញ្ញត្តិនៃកថាខណ្ឌ២ នៃមាត្រានេះ អនុវត្ត។

## មាត្រា ២៥
## ការមិនរើសអើង

១- ជនជាតិនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង មិនត្រូវជាកម្មវត្ថុនៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ចំពោះការយកពន្ធ ឬតម្រូវការណាមួយដែលពាក់ព័ន្ធទៅនឹងពន្ធ ដែលខុសពីឬមានបន្ទុកលើសពីការយកពន្ធឬតម្រូវការដែលពាក់ព័ន្ធនឹងពន្ធ លើជនជាតិនៃរដ្ឋម្ខាងទៀតនោះក្នុងកាលៈទេសៈដូចគ្នាជាពិសេសទាក់ទិននឹងនិវាសនដ្ឋាន។

២- ការកំណត់ពន្ធចំពោះគ្រឹះស្ថានអចិន្ត្រៃយ៍ ដែលសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងមាននៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មិនត្រូវទទួលបានការអនុគ្រោះលើការយកពន្ធតិចជាងសហគ្រាសរបស់រដ្ឋម្ខាងទៀតនោះ ដែលមានសកម្មភាពអាជីវកម្មដូចគ្នា។ បញ្ញត្តិនេះមិនត្រូវបានបកស្រាយថា រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ត្រូវមានកាតព្វកិច្ចផ្តល់ការអនុគ្រោះឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនូវចំណូលផ្ទាល់ខ្លួន ការអនុគ្រោះ និងការកាត់បន្ថយសម្រាប់គោលដៅសារពើពន្ធដោយសារតែស្ថានភាពគ្រួសារ ឬការទទួលខុសត្រូវក្នុងគ្រួសារដែលរដ្ឋម្ខាងនោះផ្តល់ឱ្យនិវាសនជនរបស់ខ្លួន។

៣- លើកលែងតែក្នុងករណីដែលបញ្ញត្តិនៃកថាខណ្ឌ១ នៃមាត្រា៩ កថាខណ្ឌ៧ នៃមាត្រា១១ កថាខណ្ឌ៦ នៃមាត្រា១២ ឬកថាខណ្ឌ៦ នៃមាត្រា១៣ យកមកអនុវត្ត សម្រាប់គោលដៅកំណត់ពន្ធប្រាក់ចំណេញរបស់សហគ្រាស ការប្រាក់ សួយសារ កម្រៃសេវាបច្ចេកទេស និងការចំណាយផ្សេងៗ ដែលបានទូទាត់ដោយសហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទៅឱ្យនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ត្រូវកាត់កងបានក្រោមលក្ខខណ្ឌដូចគ្នា ដូចក្នុងករណីដែលការទូទាត់ទាំងនោះ ធ្វើឡើងចំពោះនិវាសនជននៃរដ្ឋភាគីដំបូង។

៤- សហគ្រាសនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ដែលមូលធនរបស់សហគ្រាសនោះ ត្រូវបានកាន់កាប់ឬគ្រប់គ្រងទាំងស្រុងឬមួយផ្នែក ដោយផ្ទាល់ឬប្រយោល ដោយនិវាសនជនមួយឬច្រើននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត មិនត្រូវជាកម្មវត្ថុនៅក្នុងរដ្ឋភាគីដំបូង ចំពោះការយកពន្ធឬតម្រូវការណាមួយដែលពាក់ព័ន្ធទៅនឹងពន្ធ ដែលខុសពីឬមានបន្ទុកលើសពីការយកពន្ធឬតម្រូវការដែលពាក់ព័ន្ធនឹងពន្ធ ដែលត្រូវឬអាចអនុវត្តចំពោះសហគ្រាសប្រហាក់ប្រហែលគ្នាផ្សេងទៀតនៃរដ្ឋភាគីដំបូងនោះ។

៥- ពុំមានបញ្ញត្តិនៃកថាខណ្ឌខាងលើរបស់មាត្រានេះ ត្រូវបានបកស្រាយថាមានផលប៉ះពាល់ចំពោះបទប្បញ្ញត្តិនៃច្បាប់ទាំងឡាយរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនីមួយៗ
ពាក់ព័ន្ធនឹងការផ្តល់សម្បទានផ្នែកពន្ធ។

៦- ក្នុងមាត្រានេះ ពាក្យ "ការយកពន្ធ" សំដៅដល់ពន្ធទាំងឡាយណាដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ២៦
## នីតិវិធីនៃការព្រមព្រៀងទៅវិញទៅមក

១- ក្នុងករណីនិវាសជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង យល់ឃើញថាវាល់វិធានការនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬទាំងសងខាងបង្កឱ្យ ឬនឹងបង្កឱ្យមានការយកពន្ធលើបុគ្គលនោះដោយមិនអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ បុគ្គលនោះ អាចដាក់បណ្តឹងតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងដែលគាត់ជានិវាសនជន ឬទៅអាជ្ញាធរមានសមត្ថកិច្ចនៅរដ្ឋភាគីនៃកិច្ចព្រមព្រៀង ដែលគាត់មានសញ្ជាតិ ប្រសិនបើបណ្តឹងតវ៉ារបស់គាត់ស្ថិតក្រោមកថាខណ្ឌ១ នៃមាត្រា២៤ ដោយពុំគិតពីដំណោះស្រាយតាមច្បាប់ក្នុងស្រុកនៃរដ្ឋទាំងនោះ។ ការដាក់បណ្តឹងតវ៉ាត្រូវធ្វើឡើងក្នុងរយៈពេល៣ឆ្នាំ គិតចាប់ពីថ្ងៃជូនដំណឹងលើកដំបូងអំពីវិធានការនៃការយកពន្ធដែលមិនអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២- ប្រសិនបើបណ្តឹងតវ៉ាមានហេតុផលត្រឹមត្រូវ ហើយអាជ្ញាធរមានសមត្ថកិច្ចមិនអាចផ្តល់នូវដំណោះស្រាយណាមួយដែលជាទីពេញចិត្តបានទេនោះ អាជ្ញាករមានសមត្ថកិច្ចត្រូវខិតខំដោះស្រាយបណ្តឹងតវ៉ានោះតាមរយៈការព្រមព្រៀងទៅវិញទៅមកជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតក្នុងគោលបំណងចៀសវាងការយកពន្ធដែលមិនអនុលោមតាមកិច្ចព្រមព្រៀងនេះ។

៣- អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាង ត្រូវខិតខំដោះស្រាយរាល់បញ្ហា ឬចម្ងល់ផ្សេងៗដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងតាមរយៈការព្រមព្រៀងទៅវិញទៅមក។ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទាំងសងខាងអាចពិភាក្សាគ្នាផងដែរ ក្នុងគោលបំណងលុបបំបាត់ការយកពន្ធត្រួតគ្នា ទោះជាក្នុងករណីមិនមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

៤ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាងអាចធ្វើទំនាក់ទំនងគ្នាដោយផ្ទាល់ ក្នុងគោលបំណងឈានទៅដល់ការសម្រេចការព្រមព្រៀងគ្នាមួយ ស្របតាមបណ្តាកថាខណ្ឌខាងលើ។

## មាត្រា ២៧
## ការផ្លាស់ប្តូរព័ត៌មាន

១- អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងសងខាងត្រូវផ្លាស់ប្តូរព័ត៌មានទាំងឡាយ ដែលអាចរំពឹងទុកថាពាក់ព័ន្ធនឹងការអនុវត្តបញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ឬពាក់ព័ន្ធនឹងការគ្រប់គ្រងការអនុវត្ត ឬការដាក់បង្ខំឱ្យប្រតិបត្តិច្បាប់នានាក្នុងស្រុកទាក់ទិននឹងពន្ធគ្រប់ប្រភេទ និងគ្រប់ការបរិយាយដែលបានកំណត់ក្នុងនាមរដ្ឋភាគីនៃកិច្ចព្រមព្រៀង ឬអាជ្ញាធរមូលដ្ឋានដរាបណាការកំណត់ពន្ធមិនផ្ទុយនឹងកិច្ចព្រមព្រៀងនេះ។ ការផ្លាស់ប្តូរព័ត៌មានមិនត្រូវបានកំហិតដោយមាត្រា១ និងមាត្រា២ ឡើយ។

២- ព័ត៌មានដែលទទួលបានក្រោមកថាខណ្ឌ១ ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងត្រូវរក្សាទុកជាការសម្ងាត់ក្នុងលក្ខណៈដូចគ្នានឹងព័ត៌មានដែលទទួលបានក្រោមច្បាប់ក្នុងស្រុកនៃរដ្ឋនោះ និងត្រូវផ្តល់ឱ្យតែចំពោះបុគ្គល ឬអាជ្ញាធរ (រួមមានតុលាការ និងស្ថាប័នរដ្ឋបាលនានា) ទាក់ទិននឹងការកំណត់ ឬការប្រមូលពន្ធ ការដាក់បង្ខំឱ្យប្រតិបត្តិ ឬការចោទប្រកាន់តាមផ្លូវច្បាប់ ការសម្រេចលើបណ្តឹងតវ៉ាដែលពាក់ព័ន្ធទៅនឹងពន្ធដូចមានចែងក្នុងកថាខណ្ឌ១ ឬការត្រួតពិនិត្យលើសកម្មភាពដូចបានរៀបរាប់ខាងលើ។ បុគ្គល ឬអាជ្ញាធរនោះ ត្រូវប្រើប្រាស់ព័ត៌មានសម្រាប់តែក្នុងគោលបំណងដូចបានរៀបរាប់ខាងលើប៉ុណ្ណោះ។ បុគ្គល ឬអាជ្ញាធរនោះ អាចបង្ហាញព័ត៌មានបាននៅក្នុងដំណើរការនីតិវិធីតុលាការសាធារណៈ ឬនៅក្នុងសេចក្តីសម្រេចរបស់តុលាការ។ ទោះបីជាមានបញ្ញត្តិខាងលើក៏ដោយ ព័ត៌មានដែលទទួលបានពីរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងអាចត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀត ប្រសិនបើច្បាប់នៃរដ្ឋទាំងសងខាងអនុញ្ញាតឱ្យមានការប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងផ្សេងទៀតនោះ និងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដែលផ្តល់ព័ត៌មាននោះអនុញ្ញាតឱ្យប្រើប្រាស់។

៣- ទោះក្នុងករណីណាក៏ដោយ បញ្ញត្តិនៃកថាខណ្ឌ១ និង២ នៃមាត្រានេះ មិនត្រូវបានបកស្រាយថាជាការដាក់កំហិតឱ្យរដ្ឋភាគីនៃកិច្ចព្រមព្រៀងមានកាតព្វកិច្ច÷

ក. ចាត់វិធានការផ្នែករដ្ឋបាលដែលមិនស្របតាមច្បាប់ និងការអនុវត្តការងាររដ្ឋបាលរបស់រដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ ឬរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ខ. ផ្ដល់ព័ត៌មានដែលមិនអាចទទួលបានក្រោមច្បាប់ ឬដំណើរការរដ្ឋបាលជាប្រក្រតីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះ ឬរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

គ. ផ្ដល់ព័ត៌មានដែលបង្ហាញពីការសម្ងាត់ជំនួញ ធុរកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម ឬវិជ្ជាជីវៈ ឬដំណើរការជំនួញ ឬព័ត៌មានដែលផ្ទុយនឹងគោលនយោបាយសាធារណៈ (សណ្ដាប់ធ្នាប់សាធារណៈ)។

៤- ប្រសិនបើព័ត៌មានត្រូវបានស្នើសុំដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង អនុលោមតាមមាត្រានេះ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតត្រូវប្រើវិធានការក្នុងការប្រមូលព័ត៌មាន ដើម្បីប្រមូលព័ត៌មានដែលបានស្នើសុំ ទោះបីជារដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតនោះ មិនត្រូវការព័ត៌មាននោះ សម្រាប់ប្រើក្នុងគោលដៅពន្ធរបស់ខ្លួនក៏ដោយ។ កាតព្វកិច្ចដែលមានចែងក្នុងប្រយោគមុននេះ គឺអាស្រ័យលើដែនកំណត់នៃកថាខណ្ឌ៣ ប៉ុន្តែពុំមានការបកស្រាយថា ដែនកំណត់ទាំងនេះអនុញ្ញាតឱ្យរដ្ឋភាគីនៃកិច្ចព្រមព្រៀង បដិសេធក្នុងការផ្ដល់ព័ត៌មាន ដោយសារតែព័ត៌មាននោះពុំមានផលប្រយោជន៍ក្នុងស្រុក។

៥- ពុំមានករណីដែលបញ្ញត្តិនៃកថាខណ្ឌ៣ ត្រូវបានបកស្រាយថាមានការអនុញ្ញាតឱ្យរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងបដិសេធក្នុងការផ្ដល់ព័ត៌មាន ដោយសារតែព័ត៌មាននោះកាន់កាប់ដោយធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត អ្នកដែលត្រូវបានចាត់តាំង ឬបុគ្គលប្រតិបត្តិក្នុងនាមជាភ្នាក់ងារ ឬមានសមត្ថកិច្ច ឬដោយសារតែព័ត៌មាននោះ ទាក់ទិននឹងផលប្រយោជន៍នៃភាពជាម្ចាស់របស់បុគ្គលណាមួយឡើយ។

## មាត្រា ២៨
## សមាជិកបេសកកម្មទូត និងស្ថានកុងស៊ុល

កិច្ចព្រមព្រៀងនេះ មិនត្រូវប៉ះពាល់ដល់បុព្វសិទ្ធិសារពើពន្ធរបស់សមាជិកបេសកកម្មទូត ឬស្ថាន កុងស៊ុល ក្រោមវិធានទូទៅនៃច្បាប់អន្តរជាតិ ឬក្រោមបទប្បញ្ញត្តិនៃការព្រមព្រៀងពិសេសនានាទេ។

## មាត្រា ២៩
## ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹងក្រោយគេ ដែលរដ្ឋភាគីនៃកិច្ចព្រមព្រៀងទាំងពីរ ជូនដំណឹងទៅវិញទៅមកជាលាយលក្ខណ៍អក្សរតាមរយៈផ្លូវទូត អំពីការបំពេញចប់សព្វគ្រប់នូវនីតិវិធីដែលតម្រូវដោយច្បាប់ក្នុងស្រុក ដើម្បីឱ្យកិច្ចព្រមព្រៀងនេះ ចូលជាធរមាន។ កិច្ចព្រមព្រៀងនេះត្រូវមានប្រសិទ្ធភាពអនុវត្ត÷

ក. សម្រាប់ឥណ្ឌូនេស៊ី÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនទឹកប្រាក់ជាប់ពន្ធដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

(ii) ចំពោះពន្ធដទៃទៀតលើប្រាក់ចំណូល សម្រាប់ឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និង

ខ. សម្រាប់កម្ពុជា÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនទឹកប្រាក់ជាប់ពន្ធដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងឆ្នាំប្រតិទិនបន្តបន្ទាប់ទៀត និង

(ii) ចំពោះពន្ធដទៃទៀត លើប្រាក់ចំណូលដែលកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន និងឆ្នាំប្រតិទិនបន្តបន្ទាប់ទៀត។

## មាត្រា ៣០
## ការបញ្ចប់

កិច្ចព្រមព្រៀងនេះត្រូវនៅជាធរមាន រហូតដល់ពេលត្រូវបានបញ្ចប់ដោយរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង។ រដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងអាចបញ្ចប់កិច្ចព្រមព្រៀងនេះតាមរយៈផ្លូវទូតដោយជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការបញ្ចប់យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមិថុនា នៃឆ្នាំប្រតិទិនណាមួយ ក្រោយពីរយៈពេលប្រាំឆ្នាំ ចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះ ចូលជាធរមាន។ ក្នុងករណីនេះ កិច្ចព្រមព្រៀងត្រូវឈប់មានប្រសិទ្ធភាពអនុវត្ត÷

ក. សម្រាប់ឥណ្ឌូនេស៊ី÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើប្រាក់ចំណូលដែលបានកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹងស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ

(ii) ចំពោះពន្ធដទៃទៀតលើប្រាក់ចំណូល សម្រាប់ឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹងស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ និង

ខ. សម្រាប់កម្ពុជា÷

(i) ចំពោះពន្ធកាត់ទុកនៅប្រទេសប្រភព លើចំនួនទឹកប្រាក់ជាប់ពន្ធដែលបានកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹងស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ និង

(ii) ចំពោះពន្ធកម្ពុជាដទៃទៀត លើប្រាក់ចំណូលដែលបានកើតឡើងនៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំនៃការជូនដំណឹង ស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ។

ដើម្បីជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់ នៅរដ្ឋធានីហ្សាការតា ថ្ងៃទី.២៣. ខែ.តុលា. ឆ្នាំ២០១៧ និងនៅរាជធានីភ្នំពេញ ថ្ងៃទី..២៣.. ខែ.តុលា. ឆ្នាំ២០១៧ ជាភាសាឥណ្ឌូនេស៊ី ភាសាខ្មែរ និងភាសាអង់គ្លេស។ អត្ថបទទាំងអស់មានតម្លៃជាផ្លូវការស្មើគ្នា វៀរលែងតែក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

**តំណាងរដ្ឋាភិបាលនៃ**
**សាធារណរដ្ឋឥណ្ឌូនេស៊ី**

**បណ្ឌិត ស្រ្តី មុលីយ៉ានី ឥន្ទ្រាវ៉ាទី**
**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

**តំណាងរាជរដ្ឋាភិបាលនៃ**
**ព្រះរាជាណាចក្រកម្ពុជា**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

REPUBLIK INDONESIA

# PROTOKOL

Pemerintah Republik Indonesia dan Pemerintah Kerajaan Kamboja telah menyetujui pada saat penandatanganan Persetujuan untuk penghindaran pajak berganda dan pencegahan pengelakan pajak-pajak atas penghasilan bahwa ketentuan-ketentuan berikut merupakan satu bagian integral dari Persetujuan ini:

1. Untuk tujuan Pasal 5 ayat 2 subayat (h), dipahami bahwa sebuah bentuk usaha tetap mulai ada pada saat alat pengeboran atau kapal pengeboran berada dalam territorial Negara Pihak.

2. Untuk tujuan Pasal 7, dipahami bahwa tidak ada dalam Pasal ini yang akan mempengaruhi pelaksanaan setiap undang-undang dari Negara Pihak sehubungan dengan pajak yang dikenakan atas penghasilan dari asuransi, selain dari re-asuransi, dari penanggung bukan penduduk dengan bentuk usaha tetap pada Negara Pihak.

3. Untuk tujuan Pasal 10 ayat 5, dipahami bahwa batas tarif pajak tidak akan mempengaruhi ketentuan yang terdapat pada kontrak bagi hasil sehubungan dengan minyak dan gas, kontrak karya sektor pertambangan lain, yang ditandatangani oleh Negara Pihak atau perusahaan minyak dan gas milik pemerintah atau lembaganya dengan orang atau badan yang merupakan penduduk Negara Pihak lainnya.

SEBAGAI BUKTI yang bertanda tangan di bawah ini, sebagai kuasa dari Pemerintahnya masing-masing, telah menandatangani Persetujuan ini.

Dibuat dalam dua rangkap di Jakarta pada tanggal 23 Okt 2017 dan di Phnom Penh pada tanggal 13 Okt 2017 dalam bahasa Indonesia, Khmer, dan Inggris, dimana ketiga naskah tersebut mempunyai kekuatan hukum yang sama. Dalam hal terjadi perbedaan penafsiran, yang berlaku adalah naskah dalam bahasa Inggris.

UNTUK PEMERINTAH REPUBLIK INDONESIA

**Dr. SRI MULYANI INDRAWATI**

**Menteri Keuangan**

UNTUK PEMERINTAH KERAJAAN KAMBOJA

**Dr. AUN PORNMONIROTH**

**Menteri Senior**

**Menteri Ekonomi dan Keuangan**

REPUBLIK INDONESIA

## PROTOCOL

The Government of the Republic of Indonesia and the Royal Government of Cambodia have agreed at the signing of the Agreement for the avoidance of double taxation and the prevention of fiscal evasion with respect to taxes on income that the following provisions shall form an integral part of the said Agreement:

1. For the purpose of Article 5, paragraph 2, subparagraph (h), it is understood that a Permanent Establishment exists from the date on which the drilling rig or working ship is present in territory of either Contracting State.
2. For the purpose of Article 7, it is understood that nothing in this Article shall affect the application of any law of a Contracting State relating to tax imposed on income from insurance, other than re-insurance, of non-resident insurers with a permanent establishment in that Contracting State.
3. For the purpose of Article 10, paragraph 5, it is understood that the tax rate limit shall not affect the provision contained in any production sharing contracts relating to oil and gas, and contract of works for other mining sectors, concluded by a Contracting State or its relevant state oil and gas company or any other entity thereof with a person who is a resident of the other Contracting State.

IN WITNESS WHEREOF the undersigned, duly authorized thereto, have signed this Agreement.

DONE in duplicate at Jakarta on 23rd Oct 2017 and at Phnom Penh on 13th Oct 2017 in the Indonesian, Khmer, and English languages, all texts being equally authentic. In the event of any divergence of interpretation, the English text shall prevail.

| For the Government of the Republic of Indonesia | For the Royal Government of Cambodia |
| --- | --- |
| **Dr. SRI MULYANI INDRAWATI** | **Dr. AUN PORNMONIROTH** |
| **Minister of Finance** | **Senior Minister** |
| | **Minister of Economy and Finance** |

Salinan naskah resmi
*Certified true copy*

Nomor : 0203/CTC/08/2018/52
*Number*

**Sulaiman**
NIP. 19651025 199103 1 017

Sekretaris Direktorat Jenderal Hukum dan Perjanjian Internasional
Kementerian Luar Negeri, Republik Indonesia
*Secretary of Directorate General for Legal Affairs and International Treaties*
*Ministry of Foreign Affairs, Republic of Indonesia*



Tanggal : 24 Agustus 2018
*Date*

REPUBLIK INDONESIA

# ពិធីសារ

ក្នុងពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្ទុកពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានឯកភាពថា បញ្ញត្តិខាងក្រោមត្រូវក្លាយជាផ្នែកមួយ នៃកិច្ចព្រមព្រៀងនេះ÷

១. សម្រាប់គោលដៅនៃវាក្យខណ្ឌ (ជ) កថាខណ្ឌ២ ក្នុងមាត្រា៥ គ្រឹះស្ថានអចិន្ត្រៃយ៍កើតមានឡើងចាប់ពីកាលបរិច្ឆេទ ដែលគ្រឿងចក្រសម្រាប់ខួងអណ្ដូងប្រេងកាត ឬនាវាសម្រាប់ផ្គត់ផ្គង់ មានវត្តមាននៅក្នុងដែនដីនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងណាមួយ។

២. សម្រាប់គោលដៅនៃមាត្រា៧ ពុំមានករណីណាមួយនៃមាត្រានេះ ត្រូវមានផលប៉ះពាល់ដល់ការអនុវត្តច្បាប់ណាមួយនៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ទាក់ទិននឹងការកំណត់ពន្ធលើប្រាក់ចំណូលពីការលក់ធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងអនិវាសជនដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងរដ្ឋភាគីនៃកិច្ចព្រមព្រៀងនោះឡើយ លើកលែងតែការធានារ៉ាប់រងបន្ត។

៣. សម្រាប់គោលដៅនៃកថាខណ្ឌ៥ ក្នុងមាត្រា១០ការកំណត់អត្រាពន្ធនេះ មិនត្រូវមានផលប៉ះពាល់ដល់បញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យាបែងចែកផលិតផលណាមួយ ដែលទាក់ទិននឹងវិស័យប្រេង និងឧស្ម័ន ព្រមទាំងកិច្ចសន្យានៃការងារនានា ក្នុងវិស័យធនធានរ៉ែ ដែលបានបញ្ចប់រវាងរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាង ឬក្រុមហ៊ុនប្រេងនិងឧស្ម័នរដ្ឋដែលពាក់ព័ន្ធ ឬស្ថាប័នណាមួយនៃរដ្ឋនោះ ជាមួយបុគ្គលដែលជានិវាសនជន នៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។

ដើម្បីជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់នៅរដ្ឋធានីហ្សាការតា ថ្ងៃទី.២៣.ខែ.តុលា..ឆ្នាំ២០១៧ និងនៅរាជធានីភ្នំពេញ ថ្ងៃទី.១៧. ខែ.តុលា..ឆ្នាំ២០១៧ ជាភាសាឥណ្ឌូនេស៊ី ភាសាខ្មែរ និងភាសាអង់គ្លេស។ អត្ថបទទាំងអស់មានតម្លៃជាផ្លូវការស្មើគ្នា វៀរលែងតែក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាឯកសារគោល។

| | |
|---|---|
| តំណាងរដ្ឋាភិបាលនៃ | តំណាងរាជរដ្ឋាភិបាលនៃ |
| សាធារណរដ្ឋឥណ្ឌូនេស៊ី | ព្រះរាជាណាចក្រកម្ពុជា |
| បណ្ឌិត ស្រី មូលីយ៉ានី ឥន្ទ្រាវ៉ាទី | បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន |
| រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ | ទេសរដ្ឋមន្ត្រី |
| | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |